

# បុគ្គលឯក

បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើងដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្សទាំងឡាយ តើបុគ្គលឯកនោះគឺនរណា?

**"គឺព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ"**

# មាតាបិតាមានឈ្មោះ៤យ៉ាង



ភិក្ខុវជិរប្បញ្ញោ **សាន សុជា** និងញោមប្រុសស្រី

១-ជា "ព្រះព្រហ្ម" របស់កូន

២-ជា "បុព្វទេវតា" របស់កូន

៣-ជា "បុព្វាចារ្យ" របស់កូន

៤-ជា "អាហុនេយ្យបុគ្គល" របស់កូន

# មាតិកាអត្ថបទ

| ឈ្មោះធម៌ | ទំព័រ |
|---|---|


ពាក្យប្រារព្ធ ................................ ក

**IX. គាថាព្រះធម្មបទ បាបវគ្គ (ត)**

គាថាទី ១ ................................ ១

គាថាទី ២ ................................ ៤

គាថាទី ៣ ................................ ៧

គាថាទី ៤ ................................ ១១

គាថាទី ៥ ................................ ១៤

គាថាទី ៦ ................................ ១៧

គាថាទី ៧ ................................ ២០

គាថាទី ៨ ................................ ២៣

គាថាទី ៩ ................................ ២៦

គាថាទី ១០ ................................ ២៩

គាថាទី ១១ ................................ ៣២

## X. គាថាព្រះធម្មបទ ទណ្ឌវគ្គ

គាថាទី ១២ .................................... ៣៥

គាថាទី ១៣ .................................... ៣៨

គាថាទី ១៤ .................................... ៤១

គាថាទី ១៥ .................................... ៤៤

គាថាទី ១៦ .................................... ៤៨

គាថាទី ១៧ .................................... ៥១

គាថាទី ១៨ .................................... ៥៤

គាថាទី ១៩ .................................... ៥៨

គាថាទី ២០ .................................... ៦១

គាថាទី ២១ .................................... ៦៤

គាថាទី ២២ .................................... ៦៩

## XI. គាថាព្រះធម្មបទ ជរាវគ្គ

គាថាទី ២៣ .................................... ៧២

គាថាទី ២៤ .................................... ៧៥

គាថាទី ២៥ .................................... ៧៨

គាថាទី ២៦ .................................... ៨១

គាថាទី ២៧ .................................... ៨៤

គាថាទី ២៨ .................................... ៨៧

គាថាទី ២៩ .................................... ៩០

គាថាទី ៣០ .................................... ៩៣

គាថាទី ៣១ .................................... ៩៨

## XII. គាថាព្រះធម្មបទ អត្តវគ្គ

គាថាទី ៣២ .................................... ១០២

និធិកណ្ឌសូត្រ .................................... ១០៥

គោតមប្រវត្តិ .................................... ១១៣

កុំភ្លេចខ្លួន .................................... ១១៨

កំណាព្យផ្សេងៗ .................................... ១១៩

ឈ្មោះអ្នកជួយពិនិត្យអក្ខរាវិរុទ្ធ ............ ១៣០

ឈ្មោះសៀវភៅដែលបានរៀបរៀង ........ ១៣១

ប៉ុស្តិ៍វិទ្យុដែលកំពុងផ្សព្វផ្សាយព្រះធម៌ ..... ១៣២

ឈ្មោះអ្នកឧបត្ថម្ភប្រាក់បោះពុម្ពសៀវភៅនេះ ... ១៣៤

# ពាក្យប្រារព្ធ

ពុទ្ធបរិស័ទទាំងឡាយ! ពេលវេលានៃការរស់នៅរបស់មនុស្សយើងនេះ មិនសម្បូរឡើយ ធ្មេចបើក ១ ជិតដល់ពេលស្លាប់វិញទៅហើយ ហើយចំពោះជីវិតដែលខ្លីយ៉ាងនេះ តើយើងធ្លាប់បានគិតដែរឬទេថា ការងារជាប្រយោជន៍សម្រាប់ខ្លួនឯងអាត្មាអញធ្វើបានប៉ុនណាហើយ ? និងការងារដែលមិនទាន់ធ្វើ នៅមានអ្វីខ្លះទៀត ?ម្យ៉ាងទៀតការងារជាប្រយោជន៍ដល់អ្នកដទៃ និងជាប្រយោជន៍ដល់ប្រទេសជាតិ ឬក៏ដើម្បីព្រះសាសនា អាត្មាអញធ្វើបានប៉ុនណាហើយ ? តទៅខាងមុខនឹងធ្វើអ្វីទៀត ?

កាលបើយើងឧស្សាហ៍គិតយ៉ាងនេះ យើងពិត

ជាយល់ឃើញនូវតម្លៃពិតប្រាកដ របស់ពេលវេលា មិនខានឡើយ ។

តាមដែលខ្ញុំដឹង អ្នកប្រាជ្ញសម័យបុរាណខ្លះ ដូចជាសម្តេចព្រះសង្ឃរាជ ជោតញ្ញាណោ **ជួន ណាត** ជាដើម បានចំណាយពេលវេលាអស់មួយជីវិត របស់លោកទៅហើយ ក្នុងការបំពេញការងារដើម្បី ខ្លួនព្រះអង្គផ្ទាល់ ដើម្បីព្រះសាសនា និងដើម្បីប្រទេស ជាតិ ប៉ុន្តែក៏នៅមិនទាន់អស់កិច្ចការជាប្រយោជន៍ ដែលត្រូវបំពេញនោះដែរ ។

ដែលខ្ញុំលើកឡើងយ៉ាងនេះ ដើម្បីដាស់គំនិត យើងគ្រប់គ្នាថា បើពេលវេលាមិនសម្បូរយ៉ាងនេះ ហេតុអ្វីក៏យើងនៅតែចំណាយពេលវេលា ទៅក្នុងរឿង

ឥតប្រយោជន៍ផ្សេង ៗ ដូចជាការដើរលេងយប់ ការប្រព្រឹត្តអបាយមុខ ឬក៏និយាយគ្នាលេងជាដើមច្រើនម្ល៉េះ ? តើទាំងអស់គ្នានោះ ក្នុងម្នាក់ ៗ មានជីវិតប៉ុន្មាន ? ហើយអាចរស់នៅបានពេលយូរប៉ុនណាទៀត ? បើមិនបានបំពេញការងារជាប្រយោជន៍ដល់ខ្លួនឯង និងអ្នកដទៃទេ តើខ្លឹមសារនៃការរស់នៅយូរនោះ នៅត្រង់ណាខ្លះទៅ ? សូមពុទ្ធបរិស័ទបានពិចារណាដោយល្អចុះ ។

ឆ្នាំថ្មីនេះ គឺឆ្នាំជូត សំរិទ្ធិស័ក ព.ស. ២៥៥២ ខ្ញុំមានអាយុ ៣២ ឆ្នាំទៅហើយ ឃើញថាចាស់ដែរហើយ ឯមច្ចុរាជ ក៏បានបញ្ជូនសេនាមកចាត់ការជារៀងរាល់ថ្ងៃ ហើយការយកឈ្នះលើមច្ចុរាជនោះ មិនមានសោះ

ឡើយ សេចក្ដីស្លាប់ពិតជាមកដល់មិនខាន តែខ្ញុំពេញចិត្តណាស់ចំពោះពេលវេលា ដែលបានអនុញ្ញាតឱ្យខ្ញុំបំពេញការងារជាប្រយោជន៏បានបន្ដិចបន្តួច ដូចសព្វថ្ងៃនេះ មុនពេលដែលសេចក្ដីស្លាប់មកដល់ ។

ដើម្បីវាស់វែងទៅនឹងពេលវេលា ៣២ ឆ្នាំ ដែលខ្ញុំបានរស់កន្លងមកហើយ ខ្ញុំក៏លើកបទធម៌ចំនួន ៣២ ព្រះគាថា មកសរសេរប្រគេន និងចែកជូនជាធម្មទានក្នុងឱកាសបុណ្យចូលឆ្នាំថ្មីខាងមុខនេះ ។

ម្យ៉ាងទៀត ក្នុងការរៀបរៀងនេះ ខ្ញុំបានដកស្រង់ភាសាអង់គ្លេស ពីសៀវភៅធម៌បរទេស ដែលប្រែចេញពីភាសាបាលីដូចគ្នា មកសរសេរជាមួយផង ដោយសង្ឃឹមថា នឹងបានជាប្រយោជន៏ដល់អ្នកចេះភាសានេះ ។

សូមឧទ្ទិសនូវបុណ្យកុសល ដែលកើតឡើងអំពីការងារធម្មទាននេះ ចំពោះអ្នកដែលចែកឋានទៅហើយ ដូចជា -

-បុរាណបណ្ឌិតខ្មែរគ្រប់ជំនាន់

-ព្រះភិក្ខុ **ញៀម ទ៊ាន់** ជាព្រះឧបជ្ឈាយ៍របស់ខ្ញុំ

-ព្រឹទ្ធាចារ្យ **អៀង យ៉ង** ជាជីតារបស់ខ្ញុំ

-ព្រឹទ្ធាចារ្យ **ឱុន សាន** ជាជីតារបស់ខ្ញុំ

-ឧបាសិកា **សុខ គ្រីស** ជាជីដូនរបស់ខ្ញុំ

-ប្អូនប្រុស **សាន សុខ** និងប្អូនប្រុស **សាន សាវឿន**

សូមជូនចំពោះ ជីដូនរបស់ខ្ញុំ **ហែម ផាន់** ញោមប្រុស **សាន ឱុយ** ញោមស្រី **អៀង ចែម** ដែលកំពុងមានជីវិតរស់នៅសព្វថ្ងៃ និងពពួកញាតិក្នុងសង្សារវដ្តទាំងអស់ ។

មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្ន ឃុំរលាប ស្រុកសំពៅមាស
ខេត្តពោធិ៍សាត់ ប្រទេសកម្ពុជា
ថ្ងៃពុធ ៣ រោច ខែ កត្តិក ឆ្នាំ កុរ នព្វស័ក ព.ស. ២៥៥១

**ភិក្ខុវិរិយបញ្ញោ សាន សុជា**

## គាថាទី ១(១)

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវព្រះថេរៈ ឈ្មោះសេយ្យសកៈ ទើបត្រាស់នូវព្រះគាថានេះថា

**បាបញ្ចេ បុរិសោ កយិរា**
**ន នំ កយិរា បុនប្បុនំ**
**ន តម្ហិ ឆន្ទំ កយិរាថ**
**ទុក្ខោ បាបស្ស ឧច្ចយោ ។**

បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយ ៗ ឡើយ កុំគប្បីធ្វើសេចក្ដីពេញចិត្ត ក្នុងបាបនោះ ( ព្រោះថា ) ការសន្សំបាប តែងនាំសេចក្ដីទុក្ខមកឱ្យ ។

---

១-បើរាប់តាមលំដាប់ក្នុងបាបវគ្គ ត្រូវជាគាថា ទី ២

# 1. DO NO EVIL AGAIN AND AGAIN

Should a person commit evil, he should not do it again and again; he should not find pleasure therein; painful is the accumulation of evil.

បើជូនជាភ្លាំងភ្លាត់ធ្វើបាប

គួរតែប្រញាប់មានស្មារតី

កុំឱ្យបាបកើតសាជាថ្មី

ញាំញីសន្តានរឿយ ៗ ឡើយ ។

មិនត្រូវត្រេកអរក្នុងទុច្ចរិត

ដែលធ្លាប់ប្រព្រឹត្តរួចមកហើយ

ត្រូវតែសង្រួមកុំកន្តើយ

ព្រោះបាបនោះហើយនាំកើតទុក្ខ ។

*កំណាព្យបទពាក្យ ៧ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ២

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវនាងលាជទេវធីតា ទើបត្រាស់នូវព្រះគាថានេះថា

**បុញ្ញញ្ចេ បុរិសោ កយិរា**

**កយិរាថេនំ បុនប្បុនំ**

**តម្ហិ ឆន្ទំ កយិរាថ**

**សុខោ បុញ្ញស្ស ឧច្ចយោ ។**

បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឱ្យរឿយ ៗ គួរធ្វើសេចក្តីពេញចិត្ត ក្នុងបុណ្យនោះ ( ព្រោះថា ) ការសន្សំបុណ្យ តែងនាំសេចក្តីសុខមកឱ្យ ។

## 2. DO GOOD AGAIN AND AGAIN AND TAKE DELIGHT IN IT

Should a person perform a meritorious action, he should do it again and again; he should find pleasure therein: blissful is the accumulation of merit.

ការបំពេញបុណ្យ គឺសាងដើមទុន មានគុណល្អគាប់
គួរតែសន្សំ ឱ្យបានញឹកញាប់ ទៅជាទម្លាប់
កប់ក្នុងសន្តាន ។

ត្រូវចេះត្រេកអរ ក្នុងកុសលធម៌ ដែលខ្លួនធ្លាប់បាន
ចម្រើនភាវនា អប់រំសន្តាន ឬដោយសីលទាន
មានចិត្តជ្រះថ្លា ។

ព្រោះបុណ្យតែងផ្តល់ ក្តីសុខឱ្យដល់ សត្វក្នុងសង្សារ
ឱ្យរួចអបាយ សោយកាមសុខា ក្នុងមនុស្សទេវតា
សមតាមឋានៈ ។

លុះដល់អវសាន បុណ្យនាំឱ្យបាន បញ្ញាប្រចក្ស
ឃើញព្រះនិព្វាន តាមស្ពានអរិយមគ្គ រួចចាកវដ្តៈ
អន្ទាក់មច្ចុ ។

*កំណាព្យបទកាកគតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

# គាថាទី ៣

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវអនាថបិណ្ឌិកសេដ្ឋី ទើប ត្រាស់នូវព្រះគាថានេះថា

បាបោបិ បស្សតី ភទ្រំ

យាវ បាបំ ន បច្ចតិ

យទា ច បច្ចតី បាបំ

អថ ( បាបោ ) បាបានិ បស្សតិ ។

ភទ្រោបិ បស្សតី បាបំ

**យាវ ភទ្ទំ ន បច្ចតិ**

**យទា ច បច្ចតី ភទ្ទំ**

**អថ ( ភទ្រោ ) ភទ្ទានិ បស្សតិ ៗ**

បាប មិនទាន់ឱ្យផលត្រឹមណា មនុស្សបាប ក៏នៅឃើញតែសេចក្ដីចម្រើនត្រឹមណោះ លុះកាលណាបាបឱ្យផល មនុស្សបាប ទើបឃើញបាបក្នុងកាលនោះ ។

អំពើល្អ មិនទាន់ឱ្យផលត្រឹមណា មនុស្សល្អនៅឃើញតែបាបត្រឹមណោះ លុះកាលណា អំពើល្អឱ្យផល មនុស្សល្អ ទើបឃើញល្អ ក្នុងកាលនោះ ។

## 3. BY ITS EFFECTS EVIL IS KNOWN

Even an evil person may still find happiness so long as his evil deed does not bear fruit; but when his evil deed does bear fruit he will meet with evil consequences.[1]

## BY ITS EFFECTS GOOD IS KNOWN

Even a good person may still meet with suffering so long as his good deed does not bear fruit; but when it does bear fruit he will reap the benefits of his good deed.[2]

---

1.A wicked person may lead a prosperous life as the result of his past good deeds. He will experience happiness owing to the potentiality of his past good over the present evil, – a seeming injustice which often prevails in this world. When once, according to the inexorable law of kamma, his evil actions fructify, then he perceives the painful effects of his wickedness.

2.A virtuous person, as often happens, may meet with adversity owing to the potentiality of his past evil actions over his present good acts. He is convinced of the efficacy of his present good deeds only when, at the opportune moment, they fructify, giving him abundant bliss.

The fact that at times the wicked are prosperous and the virtuous are unfortunate is itself strong evidence in support of the belief in kamma and rebirth.

ដំណាំដាំដុះគ្រប់ប្រការ    តែងមានផ្លែផ្កាតាមរដូវ
ដែលទំនៀមពូជបានតម្រូវ    ច្រើនតិចក៏ត្រូវតាមពូជធារ ។
ដូចបាបក្នុងចិត្តដែលសត្វសាង    ផលមិនដែលឃ្លាងចាកកម្មា
មិនទាន់ឱ្យផលសត្វគិតថា    ល្អសោភណាគ្មានសៅហ្មង ។
លុះបាបឱ្យផលចំពោះមុខ    ទើបសត្វជួបទុក្ខពេកកន្លង
ឃើញថាពូជបាបពិតសៅហ្មង    ទោះខំដេកផ្សងក៏ឥតស្រាន្ត ។
រីឯបុណ្យក៏ស្រដៀងគ្នា    មិនទាន់ដល់គ្រាឃើញមិនបាន
លុះដល់បុណ្យផ្តល់ក្តីសុខសាន្ត    ទើបសត្វដឹងប្រាណថាល្អពិត ។

*កំណាព្យបទពាក្យ ៧ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ខ.**

## គាថាទី ៤

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុអ្នកមានបរិក្ខារមិនប្រយ័ត្ន ទើបត្រាស់នូវព្រះគាថានេះថា

**មាវមញ្ញេថ បាបស្ស ន មន្តំ អាគមិស្សតិ**

**ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ**

**អាបូរតិ ពាលោ បាបស្ស ថោកំ ថោកំបិ អាចិនំ ។**

បុគ្គល មិនគួរមើលងាយបាបថា មានប្រមាណតិច នឹងមិនឱ្យផល ដូច្នេះឡើយ ប្រៀបដូចក្អមទឹករមែងពេញបានដោយដំណក់ទឹក ដែលធ្លាក់ចុះយ៉ាងណា បុគ្គលពាល កាលសន្សំបាប សូម្បីបន្តិចម្តង ៗ គង់ពេញបានដោយបាប យ៉ាងនោះដែរ ។

## 4. THINK NOT LIGHTLY OF EVIL

Do not think lightly of evil, saying: 'It will not come to me.' Even a water-pot is filled by the falling of drops. Likewise the fool, gathering it drop by drop, fills himself with evil.

នរជនទាំងឡាយ　　កុំមើលងាយបាបទុច្ចរិត
ថាតិចឬតូចល្អិត　　ដោយគិតថាមិនឱ្យផល ។
ប្រៀបដូចក្អមទំនេរ　　ដែលគេយកទៅតម្កល់
ក្នុងទីមានភ្លៀងខ្យល់　　គង់បានផលពេញព្រៀបបាន ។
ឯបាបគ្រប់អន្លើ　　ដែលខ្លួនធ្វើទាំងប៉ុន្មាន
តិច ៗ គង់ច្រើនបាន　　ពេញសន្តានយ៉ាងនោះដែរ ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ខ.***

## គាថាទី ៥

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវសេដ្ឋី ឈ្មោះពិឡាលបទកៈ ទើបត្រាស់នូវព្រះគាថានេះថា

**មាវមញ្ញេថ បុញ្ញស្ស ន មត្តំ អាគមិស្សតិ**
**ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ**
**អាបូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ ។**

បុគ្គល មិនគួរមើលងាយបុណ្យថា មានប្រមាណតិច នឹងមិនឱ្យផលដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយដំណក់ទឹក ដែលធ្លាក់ចុះយ៉ាងណា អ្នកមានប្រាជ្ញា កាលសន្សំបុណ្យបន្តិចម្តង ៗ គង់ពេញបានដោយបុណ្យ យ៉ាងនោះ ។

## 5. THINK NOT LIGHTLY OF GOOD

Do not think lightly of good, saying: 'It will not come to me.' Even a water-pot is filled by the falling of drops, so the wise man, gathering it drop by drop, fills himself with good.

នរជនទាំងឡាយ　　កុំមើលងាយបុណ្យសុចរិត
ថាតិចឬតូចល្អិត　　ដោយគិតថាមិនឱ្យផល ។
ប្រៀបដូចក្អមទំនេរ　　ដែលគេយកទៅតម្កល់
ក្នុងទីមានភ្លៀងខ្យល់　　គង់បានផលពេញព្រៀបបាន ។
ឯបុណ្យគ្រប់អន្លើ　　ដែលខ្លួនធ្វើទាំងប៉ុន្មាន
តិច ៗ គង់ច្រើនបាន　　ពេញសន្តានយ៉ាងនោះដែរ ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ៦

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវពាណិជ អ្នកមានទ្រព្យច្រើន ទើបត្រាស់នូវព្រះគាថានេះថា

**វាណិជោវ ភយំ មគ្គំ**
**អប្បសត្ថោ មហទ្ធនោ**
**វិសំ ជីវិតុកាមោវ**
**បាបានិ បរិវជ្ជយេ ។**

បុគ្គលគួរចៀសវាងបាបទាំងឡាយ ឱ្យដូច ពាណិជដែលមានទ្រព្យច្រើន តែមានគ្នាតិច ចៀសវាង ផ្លូវគួរខ្លាច ឬដូចជាបុរសប្រាថ្នារស់នៅ ចៀសវាង ថ្នាំពិសដូច្នោះដែរ ។

## 6. SHUN EVIL

## LIKE A PERILOUS PATH

Just as a merchant, with a small escort and great wealth, avoids a perilous route; just as one desiring to live avoids poison, even so should one avoid evil.

បុគ្គលស្រឡាញ់សុខ ហើយខ្លាចទុក្ខគ្រប់ប្រការ
មិនចង់មានវេរា ត្រូវវៀរចាកបាបទាំងឡាយ ។
ដូចពាណិជមានភ័ព្វ ជញ្ជូនទ្រព្យទៅទីឆ្ងាយ
តែងចៀសផ្លូវអន្តរាយ ទោះវាងឆ្ងាយក៏មិនថា ។
ឬដូចជាបុរស ដែលចង់រស់រាល់អាត្មា
មិនចង់អស់សង្ខារ វៀរថ្នាំពិសដូច្នោះដែរ ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ៧

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវអ្នកនេសាទឈ្មោះកុក្កុដមិត្រ ទើបត្រាស់នូវព្រះគាថានេះថា

**បាណម្ហិ ចេ វណោ នាស្ស**

**ហរេយ្យ បាណិនា វិសំ**

**នាព្វណំ វិសមន្វេតិ**

**នត្ថិ បាបំ អកុព្វតោ ។**

បើដំបៅមិនមានក្នុងបាតដៃទេ បុគ្គលគប្បីនាំយកថ្នាំពិសដោយបាតដៃ ថ្នាំពិសតែងមិនជ្រាបចូលទៅកាន់បាតដៃដែលគ្មានដំបៅ យ៉ាងណា បាប រមែងមិនមានដល់បុគ្គលអ្នកមិនធ្វើ យ៉ាងនោះដែរ ។

# 7. NO EVIL BEFALLS THOSE WHO HAVE NO BAD INTENTOIN

If no wound there be in one's hand, one may carry poison in it. Poison does not affect one who has no wound. There is no ill for him who does no wrong.[1]

---

1. That is, for one who has no evil intention.

បើសិនបាតដៃឥតដំបៅ

ទោះបីលូកទៅក្នុងថ្នាំពុល

ថ្នាំពិសមិនអាចជ្រាបចូលដល់

ព្រោះហេតុពីផលស្បែកជិតល្អ ។

យ៉ាងណាធម្មជាតិបាបទុច្ចរិត

បើមិនប្រព្រឹត្តមិនត្រេកអរ

សន្ដានចិត្តពិតស្រិតបានស

ឯបាបនោះក៏មិនមានឡើយ ។

*កំណាព្យបទពាក្យ ៧ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ៨

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវព្រានឆ្កែ ឈ្មោះកោកៈ ទើប ត្រាស់នូវព្រះគាថានេះថា

**យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ**

**សុទ្ធស្ស បោសស្ស អនង្គណស្ស**

**តមេវ ពាលំ បច្ចេតិ បាបំ**

**សុខុមោ រជោ បដិវាតំវ ខិត្តោ ។**

បុគ្គលណា ប្រទូស្តចំពោះអ្នកមិនប្រទូស្តតប ជាសត្វស្អាត មិនមានកិលេសដូចជាទីទួល បាបរមែង ត្រឡប់មករកបុគ្គលពាលនោះវិញ ដូចធូលីល្អិត ដែល បុគ្គលបាចសាចទៅកាន់ទីច្រាសខ្យល់ ។

## 8. WHO HARMS THE INNOCENT COMES TO GRIEF

Whoever harms a harmless person, one pure and guiltless, upon that very fool the evil recoils like fine dust thrown against the wind.

បើបុគ្គលណា មានចិត្តឫស្យា ប្រទូសរ៉ាយ
ចំពោះបុគ្គល អ្នកស្អាតទាំងឡាយ ស្អាតវាចាកាយ
ស្អាតចិត្តសន្ដាន ។
បាបដែលគេធ្វើ តែមួយដំណើរ មិនយូរប៉ុន្មាន
មុខជាត្រឡប់ ផលតបមិនខាន ឱ្យទុក្ខដល់ប្រាណ
ឥតមានយោគយល់ ។
ដូចធូលីខ្សាច់ ដែលបុគ្គលបាច កាន់ទីច្រាសខ្យល់
តែមួយរំពេច ពិតជាបានផល ត្រឡប់មកដល់
អ្នកបាចប្រាកដ ។

*កំណាព្យបទកាកគតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ឌ.***

## គាថាទី ៩

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះតិស្សត្ថេរ អ្នកជិតដិតក្នុងត្រកូលនៃជាងកែវមណី ទើបត្រាស់នូវព្រះគាថានេះថា

**គព្ភមេកេ ឧប្បជ្ជន្តិ**

**និរយំ បាបកម្មិនោ**

**សគ្គំ សុគតិនោ យន្តិ**

**បរិនិព្វន្តិ អនាសវា ។**

ជនពួកខ្លះ កើតក្នុងគភ៌មនុស្ស ពួកអ្នកមានអំពើអាក្រក់ ទៅកាន់នរក ពួកអ្នកមានគតិល្អ ទៅកាន់ឋានសួគ៌ ពួកអ្នកមិនមានអាសវៈ បរិនិព្វាន ។

# 9. BIRTH DEPENDS ON ACTIONS

Some are reborn[1] as human beings, the wicked are reborn in woeful states,[2] the righteous go to blissful states,[3] and those who are free[4] from mental defilements pass away into Nibbāna.

---

1. According to Buddhism there are four kinds of birth - namely, egg-born (*aṇḍaja*), womb-born (*jalābuja*), moisture-born (*saṁsedaja*), and spontaneous birth (*opapātika*).

2. *Niraya* = *ni* + *aya* = devoid of happiness. There are four kinds of *niraya* – namely, woeful state (*apāya*), the animal kingdom (*tiracchānayoni*), the plane of Petas (*petayoni*) and the plane of Asura-demons (*asurayoni*).None of these states is eternal. According to their evil kamma beings may be born in such woeful states. Departing from those states, they may be born in blissful states according to their past good kamma.

3. *Sagga* = *su* + *agga* = full of happiness. In the sense-sphere (*kāmaloka*) the human plane and the six celestial planes are regarded as blissful states. They too are not eternal .

4. Arahants, after death, are not born any more, but attain Parinibbāna.

បើអាសវៈនៅមាន សត្វគ្រប់ប្រាណនៅតែកើត
វិលស្លាប់ផ្លាស់កំណើត កើតព្រោះកម្មសាងពីនាយ ។
សត្វខ្លះកើតក្នុងគភ៌ ទីមិនល្អគឺពោះម្ដាយ
ដេកត្រាំដប់ខែឬាយ គួរនឿយណាយគួរជិនឆ្អន់ ។
អ្នកមានកម្មអាក្រក់ ធ្លាក់នរករាប់អនន្ត
សោយទុក្ខជាទម្ងន់ កូនប្រពន្ធជួយមិនបាន ។
អ្នកមានគតិល្អ បានត្រេកអរក្នុងសួគ៌ឋាន
ក៏នៅតែមិនបាន រួចចាកឋានមច្ចុមារ ។
ឯអ្នកអស់អាសវៈ រួចអន្ទាក់គ្រប់ប្រការ
គ្មានបំណុលសង្ខារ ចរយាត្រាទៅនិព្វាន ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ឌ.***

# គាថាទី ១០

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវជន ៣ ពួក ទើបត្រាស់នូវព្រះគាថានេះថា

**ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ**
**ន បព្វតានំ វិវរំ បវិស្ស**
**ន វិជ្ជតី សោ ជគតិប្បទេសោ**
**យត្រដ្ឋិតោ មុច្ចេយ្យ បាបកម្មា ។**

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅពួជអាកាស ក្នុងកណ្ដាលសមុទ្រ កាន់ចន្លោះភ្នំទាំងឡាយក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដីដែលបុគ្គលឋិតនៅហើយ គប្បីរួចចាកបាបកម្មបាននោះ មិនដែលមានឡើយ ។

## 10. NOBODY IS EXEMPT FROM THE EFFECTS OF EVIL KAMMA

Not in the sky, nor in mid-ocean, nor in a mountain cave, is found that place on earth where abiding, one may escape from (the consequences of) one's evil deed.

បុគ្គលបានសាងបាបទុកពីនាយ
មិនអាចដោះកាយឱ្យឆ្ងាយផលកម្ម
បើទុកជាពេលកន្លងយូរឆ្នាំ
បាបនៅតែចាំតាមចូលមកដុត ។
សូម្បីចូលទៅឯអាកាសា
ឬជ្រែកជលសាចូលក្នុងសមុទ្រ
ចូលចន្លោះភ្នំធំខ្ពស់បំផុត
ក៏មិនអាចរត់ពីផលបាបបាន ។
ព្រោះត្បិតឋិតលើផែនពសុធា
សត្វគ្រប់អង្គាដែលអាចលាក់ប្រាណ
ឱ្យរួចពីបាបដែលខ្លួនធ្លាប់បាន
សាងធ្វើប៉ុន្មានមិនដែលមានឡើយ ។

*កំណាព្យបទពាក្យ ៨ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

## គាថាទី ១១

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង និគ្រោធារាម ទ្រង់ប្រារព្ធនូវស្តេចសាក្យៈ ឈ្មោះ សុប្បពុទ្ធ ទើបត្រាស់នូវព្រះគាថានេះថា

**ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ**
**ន បព្វតានំ វិវរំ បវិស្ស**
**ន វិជ្ជតី សោ ជគតិប្បទេសោ**
**យត្រដ្ឋិតំ នប្បសហេយ្យ មច្ចូ ។**

បុគ្គលទៅ ព្ធដ៏អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្លោះនៃភ្នំទាំងឡាយ ក៏មិនរួចចាកសេចក្តីស្លាប់បាន ព្រោះប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយ សេចក្តីស្លាប់គ្របសង្កត់មិនបាននោះ មិនដែលមានឡើយ ។

# 11. DEATH CANNOT BE OVERCOME

Not in the sky, nor in mid-ocean, nor in a mountain cave, is found that place on earth where abiding, one will not be overcome by death.

បុគ្គលកាលស្ទុះទៅ　　កាន់ទិសដៅឆ្ងាយយ៉ាងណា
ចូលកាន់អាកាសា　　ជ្រែកជលសាចូលសមុទ្រ ។
ឬចូលកាន់ចន្លោះ　　ភ្នំដែលខ្ពស់ធំបំផុត
ក៏មិនអាចនឹងរត់　　គេចឱ្យផុតក្តីស្លាប់បាន ។
ត្បិតលើផែនពសុធា　　មច្ចុមារតែងទន្ទ្រាន
កើតហើយត្រូវតែមាន　　ទីអវសានគឺក្តីស្លាប់ ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ១២[១]

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុអ្នកប្រព្រឹត្តរួមគ្នា ជាពួក ៦ រូប ទើបត្រាស់នូវព្រះគាថានេះថា

**សព្វេ តសន្តិ ទណ្ឌស្ស**

**សព្វេ ភាយន្តិ មច្ចុនោ**

**អត្តានំ ឧបមំ កត្វា**

**ន ហនេយ្យ ន ឃាតយេ ។**

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំងឡាយ តែងខ្លាចចំពោះសេចក្តីស្លាប់គ្រប់ៗរូប បុគ្គលគួរធ្វើខ្លួនឱ្យជាឧបមា ហើយមិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឱ្យប្រហារឡើយ ។

---

១-បើរាប់តាមលំដាប់ក្នុងទណ្ឌវគ្គ ត្រូវជាគាថា ទី ១

# 12. KILL NOT

All tremble at the rod (punishment). All fear death. Comparing others with oneself, one should neither strike nor cause to strike.

សត្វក្នុងលោកា តែងខ្លាចរអា នឹងអាជ្ញាទណ្ឌ

ខ្លាចការបៀតបៀន ឈ្លានពានជិះជាន់ ខ្វះក៏បន់ស្រន់

សុំក្តីសុខា ។

ភ័យធំបំផុត គឺតែងតក់ស្លុត នឹងក្តីមរណា

បុគ្គលធ្វើខ្លួន ឱ្យជាឧបមា មិនគួរប្រហារ

ជីវិតសត្វឡើយ ។

*កំណាព្យបទកាកគតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

## គាថាទី ១៣

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុអ្នកប្រព្រឹត្តរួមគ្នា ជាពួក ៦ រូប ទើបត្រាស់នូវព្រះគាថានេះថា

**សព្វេ តសន្តិ ទណ្ឌស្ស**

**សព្វេសំ ជីវិតំ បិយំ**

**អត្តានំ ឧបមំ កត្វា**

**ន ហនេយ្យ ន ឃាតយេ ។**

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា (ព្រោះថា) ជីវិតជាទីស្រឡាញ់របស់សត្វទាំងពួង បុគ្គលគួរធ្វើខ្លួនឱ្យជាឧបមា ហើយមិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឱ្យប្រហារឡើយ ។

# 13. LIFE IS DEAR TO ALL

All tremble at the rod (punishment). Life is dear to all. Comparing others with oneself, one should neither strike nor cause to strike.

សត្វលោកកើតមកតែងតែភ័យខ្លាច

អំពើកោងកាចដោយទណ្ឌអាជ្ញា

ព្រោះត្បិតសត្វលោករាល់រូបអាត្មា

តែងតែត្រូវការស្រឡាញ់ជីវិត ។

បុគ្គលធ្វើខ្លួនឱ្យជាឧបមា

មិនគួរប្រហារឱ្យសត្វភ័យភិត

គួរតែបង្កើនមេត្តាអាណិត

ឱ្យកើតក្នុងចិត្តអស់កាលដរាប ។

*កំណាព្យបទពាក្យ ៨ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

# គាថាទី ១៤

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវកុមារតូច ៗ ច្រើនរូប ទើបត្រាស់នូវព្រះគាថានេះថា

សុខកាមានិ ភូតានិ
យោ ទណ្ឌេន វិហឹសតិ
អត្តនោ សុខមេសានោ
បេច្ច សោ ន លភតេ សុខំ ។

សុខកាមានិ ភូតានិ
យោ ទណ្ឌេន ន ហឹសតិ
អត្តនោ សុខមេសានោ
បេច្ច សោ លភតេ សុខំ ។

ជនណា ស្វែងរកសេចក្ដីសុខ ដើម្បីខ្លួន តែបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្ដីសុខ ដោយអាជ្ញា ជននោះលះលោកនេះទៅហើយ នឹងមិនបានសេចក្ដីសុខឡើយ ។

ជនណា ស្វែងរកសេចក្ដីសុខ ដើម្បីខ្លួន តែមិនបៀតបៀនសត្វទាំងឡាយ អ្នកដែលប្រាថ្នាសេចក្ដីសុខ ដោយអាជ្ញា ជននោះលះលោកនេះទៅហើយ រមែងបានសេចក្ដីសុខ ។

# 14.MOLEST NONE

He who seeks his own happiness by harming others who also desire to have happiness will not find happiness hereafter.

# HARM NOT

He who seeks his own happiness by not harming others who also desire to have happiness will find happiness hereafter.

ថាបើបុគ្គលណា ខ្លាចរអានឹងក្តីទុក្ខ
ស្វែងរកសេចក្តីសុខ មកដើម្បីតែខ្លួនឯង ។
ប៉ុន្តែទៅប្រហារ សត្វផងគ្នាឱ្យចំបែង
ឥតមានការកោតក្រែង ដោយអាជ្ញាគ្មានប្រណី ។
អ្នកនោះលុះបែកកាយ ទៅលោកនាយសាជាថ្មី
មិនបានសុខសួស្តី ដូចមានអ្នកតាមចាក់រុក ។
ថាបើបុគ្គលណា ខ្លាចរអានឹងក្តីទុក្ខ
ស្វែងរកសេចក្តីសុខ មកប្រគល់ឱ្យខ្លួនឯង ។
ប៉ុន្តែមិនប្រហារ សត្វផងគ្នាឱ្យចំបែង
ដោយមានការកោតក្រែង ចេះសន្តោសប្រោសប្រណី ។
អ្នកនោះលុះបែកកាយ ទៅលោកនាយសាជាថ្មី
តែងបានសុខសួស្តី ព្រោះចង្រៃមិនមានឡើយ ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ១៥

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះកោណ្ឌធានត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

មាវោច ផរុសំ កញ្ចិ
វុត្តា បដិវទេយ្យុ តំ
ទុក្ខា ហិ សារម្ភកថា
បដិទណ្ឌា ផុសេយ្យុំ តំ ។
សចេ នេរេសិ អត្តានំ
កំសោ ឧបហតោ យថា
ឯស បត្តោសិ និព្វានំ
សារម្ភោ តេ ន វិជ្ជតិ ។

អ្នកកុំនិយាយពាក្យអាក្រក់ នឹងអ្នកណាមួយឡើយ ជនទាំងឡាយដែលអ្នកស្តីថាឱ្យហើយ គេគប្បីស្តីថាតបមកអ្នកវិញ ព្រោះថា ការពោលពាក្យប្រណាំងប្រជែង ជាហេតុនាំឱ្យកើតទុក្ខ ការតស៊ូទាំងឡាយ គប្បីប៉ះពាល់នូវអ្នក ។

បើអ្នកធ្វើខ្លួនមិនឱ្យញាប់ញ័រ ដូចរគាំងដែលចៀរមាត់ចេញហើយ (រមែងមិនលាន់ឮសូរ) ដូច្នោះ អ្នកនុ៎ះជាបុគ្គលដល់នូវព្រះនិព្វាន ការប្រណាំងប្រជែងមិនមានដល់អ្នក ។

## 15. SPEAK NOT HARSHLY

Don't speak harshly to anyone; those who are thus spoken to will retort. Malicious talk is indeed the cause of trouble (*dukkha*) and retribution will come to you.

## SILENCE YOURSELF

If you can keep yourself calm and quiet, like a broken gong which is no longer resonant, you are sure to realise Nibbāna;[1] there will be no harshness in you.

---

1.One who follows this exemplary practice, even though not yet having attained Nabbāna, is regarded as having attained Nibbāna.

ពាក្យអាក្រក់ ដូចលាមក ផ្សាយច្រាសខ្យល់
រមែងផ្តល់ ផលតបស្នង មកដល់កាយ
ព្រោះអ្នកស្តាប់ គេឈឺចាប់ ក្តៅក្រហាយ
រកឧបាយ ស្រាយកំហឹង ប្តឹងតវ៉ា ។
បើធ្វើហី មិនស្រដី ទុក្ខាសិត
សម្រួលចិត្ត គិតឱ្យល្អ សឹមវាចា
ដូចរគាំង ចៀរមាត់ខាង លែងឡូឡា
ព្រះសាស្តា ថាអ្នកដល់ ព្រះនិព្វាន ។

*កំណាព្យបទពាក្យ ៩ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

# គាថាទី ១៦

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តបុព្វារាម ទ្រង់ប្រារព្ធនូវឧបោសថកម្ម របស់ ឧបាសិកាទាំងឡាយ មានមហាឧបាសិកាវិសាខា ជាដើម ទើបត្រាស់នូវព្រះគាថានេះថា

**យថា ទណ្ឌេន គោបាលោ**

**គាវោ បាជេតិ គោចរំ**

**ឯវំ ជរា ច មច្ចុ ច**

**អាយុំ បាជេន្តិ បាណិនំ ។**

គង្វាលគោ រមែងក្បៀងគោទៅកាន់ទីគោចរ ដោយអាជ្ញា ដូចម្ដេចមិញ ជរានិងមច្ចុ តែងក្បៀង អាយុរបស់សត្វទាំងឡាយ ដូច្នោះឯង ។

# 16. DECAY AND DEATH ARE UNIVERSAL

As with a staff the herdsman[1] drives his kine[2] to pasture,[3] even so do old age and death drive out the lives of beings.

---

1. Here the herdsman resembles decay and death.

2. The cattle resembles life.

3. The pasture ground resembles death.

នាយគង្វាលគោ  រមែងកៀងគោ  កាន់ទីគោចរ

គឺទីមានស្មៅ  និងទឹកថ្លាល្អ  ជាទីត្រេកអរ

នៃគោទាំងឡាយ ។

រីឯជរា  និងមច្ចុមារ  តែងមានឧបាយ

កៀងយកអាយុ  នៃសត្វទាំងឡាយ  ឱ្យចាស់បែកកាយ

ក៏ដូច្នោះដែរ ។

*កំណាព្យបទកាកគតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ១៧

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវអជគរប្រេត ទើបត្រាស់នូវព្រះគាថានេះថា

**អថ បាបានិ កម្មានិ**

**ករំ ពាលោ ន ពុជ្ឈតិ**

**សេហិ កម្មេហិ ទុម្មេធោ**

**អគ្គិទឌ្ឍោវ តប្បតិ ។**

បុគ្គលមិនមានប្រាជ្ញា កាលធ្វើអំពើអាក្រក់រមែងមិនភ្ញាក់ខ្លួន លុះកាលជាខាងក្រោយ ទើបក្តៅក្រហាយ ដោយសារកម្មរបស់ខ្លួន ដូចត្រូវភ្លើងឆេះ ។

# 17. NO ESCAPE FROM EVIL

So, when a fool does wrong deeds, he does not realize (their evil nature); by his own deeds the fool is tormented, like one burnt by fire.

បុគ្គលទុម្មេធោ    ត្រូវមោហបាំងប្រាជ្ញា

ធ្វើបាបពេញចិន្តា    ភ្លេចអាត្មាមិនភ្ញាក់ខ្លួន ។

លុះពេលជាខាងក្រោយ    បាបតាមឱ្យផលផ្ទួន ៗ

ដោយសារតែកម្មខ្លួន    ក្តៅក្រហាយដូចភ្លើងឆេះ ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ឌ.***

## គាថាទី ១៨

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវព្រះមហាមោគ្គល្លានត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

យោ ទណ្ឌេន អទណ្ឌេសុ អប្បទុដ្ឋេសុ ទុស្សតិ
ទសន្នមញ្ញតរំ ឋានំ ខិប្បមេវ និគច្ឆតិ
វេទនំ ផរុសំ ជានឹ សរីរស្ស វ ភេទនំ
គរុកំ វាបិ អាពាធំ ចិត្តក្ខេបំ វ បាបុណេ
រាជតោ វា ឧបសគ្គំ អព្ភក្ខានំ វ ទារុណំ
បរិក្ខយំ វ ញាតីនំ ភោគានំ វ បភង្គុណំ
អថវស្ស អគារានិ អគ្គិ ឌហតិ បាវកោ
កាយស្ស ភេទា ទុប្បញ្ញោ និរយំ សោ ឧបបជ្ជតិ ។

បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ ដែលមិនមានអាជ្ញា មិនប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្តីទុក្ខណាមួយ ក្នុងហេតុ ១០ យ៉ាង ដោយទាន់ហន់ គឺគប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្តីវិនាសទ្រព្យ ១ បែកធ្លាយសរីរៈ ១ អាពាធជាទម្ងន់ ១ ក្រឡកចិត្ត (ឆ្កួត) ១ រីបជាន់អំពីស្តេច ១ ពោលពាក្យបង្កាច់ដ៏អាក្រក់ ១ អស់ពួកញាតិរលីង ១ ពុកផុយភោគ-សម្បត្តិទាំងឡាយ ១ ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ ១ បុគ្គលមិនមានប្រាជ្ញានោះលុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។

# 18. HE WHO OFFENDS THE INNOCENT COMES TO GRIEF

He who does harm with weapons to those who are harmless[1] and should not be harmed will soon suffer any of these ten evil consequences. He will be subject to acute pain,[2] disaster, bodily injury, or even grievous sickness, or loss of mind, or oppression by the king, or heavy accusation, or loss of relatives, or destruction of wealth,[3] or ravaging fire that will burn his house. Upon the dissolution of the body the fool will be reborn in hell.

---

1. Namely, the Arahants who are weaponless and innocent.
2. That might cause death.
3. Loss in business transactions, loss of wealth, etc.

បើបុគ្គលណាមានចិត្តទ្រុស្ត    បៀតបៀនប្រទូស្តដោយអាជ្ញា
លើជនស្លូតត្រង់ផងនានា    អ្នកមានអាជ្ញាដាក់ចុះហើយ ។
បុគ្គលនោះឯងតែងជួបទុក្ខ    ដប់មុខណាមួយឥតស្រាកស្បើយ
រត់គេចក៏គេចមិនរួចឡើយ    ព្រោះកម្មធ្វើហើយតាមប្រហារ ។
មួយបានវេទនាដ៏អាក្រក់    ពីរបែកសរីរៈគួរអនិច្ចា
បីវិនាសទ្រព្យគាប់ចិន្តា    បួនកើតរោគាជាទម្ងន់ ។
ទីប្រាំតែងឆ្កួតក្រឡកចិត្ត    ប្រាំមួយនោះពិតស្តេចជិះជាន់
ប្រាំពីរគេពោលមួលបំភាន់    ប្រាំបីធ្លាក់ខ្លួនញាតិដោះដៃ ។
ប្រាំបួនពុកផុយទ្រព្យសម្បត្តិ    ទីដប់វិបត្តិគ្រោះចង្រៃ
ត្រូវភ្លើងឆេះផ្ទះទ្រូងរឹងរៃ    ក្រោយពេលខ្លួនក្ស័យទៅនរក ។

*កំណាព្យបទពាក្យ ៧ ដោយ  ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ឌ.**

# គាថាទី ១៩

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុអ្នកមានភណ្ឌៈច្រើន ទើបត្រាស់នូវព្រះគាថានេះថា

**ន នគ្គចរិយា ន ជដា ន បង្កា**
**នានាសកា ថណ្ឌិលសាយិកា វា**
**រជោជល្លំ ឧក្កុដិកប្បធានំ**
**សោធេន្តិ មច្ចំ អវិតិណ្ណកង្ខំ ។**

ការប្រព្រឹត្តអាក្រាតកាយ ទុកសក់ ដេកលើភក់ មិនបរិភោគបាយ ដេកលើផែនដី ប្រឡាក់ខ្លួនដោយធូលី ព្យាយាមអង្គុយច្រហោង មិនជម្រះសត្វដែលមិនទាន់ឆ្លងផុតសេចក្ដីសង្ស័យបានទេ។

# 19. EXTERNAL PENANCES CANNOT PURIFY A PERSON

Not wandering naked,[1] nor matted locks,[2] nor filth,[3] nor fasting,[4] nor lying on the ground,[5] nor dust,[6] nor ashes,[7] nor striving to squat on the heels,[8] can purify a mortal who has not overcome doubts.[9]

---

1. Gymnosophism is still practised in India. External dirtiness is regarded by some as a mark of saintliness. The Buddha denounces strict asceticism confined to such externals. The members of his celibate Order follow the middle path, avoiding the extremes of self-mortification and self-indulgence. Simplicity, humility, and poverty should be the chief characteristics of bhikkhus as much as cleanliness.

2. Unwashed matted hair is regarded by the foolish as a mark of holiness.

3. The non-cleansing of teeth, smearing the body with mud, etc.

4. Fasting alone does not lead to purification. The bhikkhus too fast daily between midday and the following dawn.

5. Sleeping on the ground. Bhikkhus only avoid luxurious and high couches.

6. Through not bathing.

7. Rubbing the body with ashes is still practised by some ascetics.

8. Continually sitting and wandering in that posture.

9. With regard to the Buddha, Dhamma, Sangha, etc.

ប្រព្រឹត្តអាក្រាតកាយ　　មិនឆីបាយដេកលើភក់
ដេកដីឬទុកសក់　　ប្រឡាក់ខ្លួនដោយធូលី ។
ព្យាយាមឈរចំកោង　　ឬច្របោងគ្រប់វិធី
មិនអាចឆ្លងធូលី　　ក្តីសង្ស័យឱ្យផុតបាន ។
លុះតែកសាងគុណ　　បំពេញបុណ្យក្នុងសន្តាន
សាងមគ្គធ្វើជាស្ពាន　　ទើបឆ្លងបានអស់សង្ស័យ ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ២០

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវសន្តតិមហាមាត្យ ទើបត្រាស់នូវព្រះគាថានេះថា

**អលង្កតោ ចេបិ សមំ ចរេយ្យ**
**សន្តោ ទន្តោ និយតោ ព្រហ្មចារី**
**សព្វេសុ ភូតេសុ និធាយ ទណ្ឌំ**
**សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ ។**

បើបុគ្គលណាមានខ្លួន ប្រដាប់ស្អិតស្អាងហើយ (ដោយគ្រឿងអម្ពរ) តែគប្បីប្រព្រឹត្តស្មើ អ្នកស្ងប់រម្ងាប់ ទូន្មាន (ឥន្ទ្រិយ) ជាបុគ្គលទៀង (ចំពោះមគ្គផល) អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញាក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះ ហៅថាព្រាហ្មណ៍ក៏បាន ថាសមណៈក៏បាន ថាភិក្ខុក៏បាន ។

# 20. NOT BY EXTERNAL APPEARANCE DOES ONE BECOME HOLY

Though gaily decked if he should live in peace, (with passions) subdued, (and senses) controlled, certain[1] (of the four Paths of Sainthood), perfectly pure,[2] laying aside the rod (in his relations) towards all living beings[3] a Brāhmana[4] indeed is he, an ascetic[5] is he, a bhikkhu[6] is he.

---

1. *Niyata.* The four Paths are *Sotāpatti* (Stream-Winner), *Sakadāgāmi* (Once-Returner), *Anāgāmi* (Never-Returner), and *Arahatta* (Worthy).

2. Mrs. Rhys Davids: 'Walking in God', a very misleading phrase, totally foreign to Buddhism. The commentarial explanation is *seṭṭhacariya* – highest conduct.

3. Absolutely harmless towards all.

4. Because he has cast aside impurities.

5. *Samaṇa*, because he has cleansed himself of all impurities.

6. Bhikkhu, because he has destroyed passions.

បានឈ្មោះសមណៈឬមួយជាព្រាហ្មណ៍
មិនមែនបាននាមតែត្រឹមកោរសក់
សូម្បីខ្លួនបួសតែចិត្តអាក្រក់
បួសចិត្តលាមកនោះហៅបួសប្លម ។
អ្នកដែលកំពុងទ្រទ្រង់អលង្ការ
តែមានប្រាជ្ញាចរិយាសមរម្យ
មិនបានបៀតបៀនសព្វសត្វតូចធំ
ទូន្មានអប់រំឥន្ទ្រិយជាក់លាក់ ។
ប្រព្រឹត្តតាមធម៌ជាបុគ្គលទៀង
ជាអ្នកមិនឃ្វាងចាកអរិយមគ្គ
អាចហៅភិក្ខុឬជាសមណៈ
ហៅឱ្យសមស័ក្តិថាព្រាហ្មណ៍ក៏បាន ។

*កំណាព្យបទពាក្យ ៨ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ឌ.***

## គាថាទី ២១

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវបិលោតិកត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

ហិរីនិសេធោ បុរិសោ
កោចិ លោកស្មិ វិជ្ជតិ
យោ និទ្ទំ អបពោធេតិ
អស្សោ ភទ្រោ កសាមិវ ។
អស្សោ យថា ភទ្រោ កសានិវិដ្ឋោ
អាតាបិនោ សំវេគិនោ ភវាថ
សទ្ធាយ សីលេន ច វីរិយេន ច
សមាធិនា ធម្មវិនិច្ឆយេន ច

## សម្បន្នវិជ្ជាចរណា បតិស្សតា
## បហស្សថ ទុក្ខមិទំ អនប្បកំ ។

បុរសអ្នកកម្ចាត់បង់នូវអកុសលវិតក្កៈ ដោយសេចក្ដីខ្មាសបាប មានតិចក្នុងលោក បុគ្គលណាបន្ទោបង់នូវការដេកលក់ ដូចសេះល្អខ្លាចព្រោះរំពាត់ បុរសនោះ រកបានដោយក្រក្នុងលោក ។

សេះល្អ ដែលនាយសារថីទូន្មាន ដោយរំពាត់ តក់ស្លុតយ៉ាងណា អ្នកទាំងឡាយ ចូរជាបុគ្គលមានព្យាយាម មានសេចក្ដីតក់ស្លុតយ៉ាងនោះឯង បើអ្នកទាំងឡាយ ប្រកបព្រមដោយសទ្ធាផង សីលផង ព្យាយាមផង.សមាធិផង ធម្មវិនិច្ឆ័យផង ជាអ្នកមានវិជ្ជានិងចរណៈដ៏បរិបូណ៌ មានស្មារតីតម្កល់មាំ រមែងលះបង់ទុក្ខ មានប្រមាណច្រើននេះមិនខាន ។

# 21. THE MODEST ARE RARE IN THIS WORLD

Rare in this world is the kind of person who out of a sense of shame restrains from doing evil and keeps himself awake like a good horse that gives no cause to be whipped.[1]

1. A self-respecting bhikkhu or layman, when obsessed with evil thoughts, tries to eradicate them there and then. This verse indicates that such persons are rare.

# BE VIRTUOUS AND GET RID OF SUFFERING

Like a thorough-bred horse, touched by the whip, even so be strenuous and zealous. By confidence, by virtue, by effort, by concentration, by investigation of the Truth, by being endowed with knowledge and conduct,[2] and by being mindful, get rid of this great suffering.

---

2. *Vijjācaraṇa.* Eight kinds of Knowledge and fifteen kinds of Conduct. The eight kinds of Knowledge are:

(1) Psychic Powers (*Iddhividha*), (2) Divine Ear (*Dibba-sota*), (3) Penetration of the minds of others (*Ceto-pariya-ñāṇa*), (4) Divine Eye (*Dibbacakkhu*), (5) Remembrance of former births (*Pubbenivāsa-nussati*), (6) Extinction of corruptions (*Asavakkhaya*), (7) Insight (*Vipassanā*), and (8) Creation of mental images (*Manomayiddhi*).

The fifteen kinds of Conduct are:–

Moral restraint, sense-restraint, moderation in eating, wakefulness, faith, moral shame, moral dread, great learning, energy, mindfulness, wisdom and the four *Jhanas*.

សេះដែលសារថីខំប្រឹងបង្ហាត់
ដោយប្រើរំពាត់ឬជន្លួញដែក
សារថីបរទៅមិនហ៊ានប្រកែក
តក់ស្លុតក្រែពេកខំស្ទុះទៅមុខ ។
ឯអ្នកទាំងឡាយចូរតាំងព្យាយាម
មិនត្រូវទាក់ទាមក្នុងប្រភពទុក្ខ
ត្រូវតែកាន់ធម៌យកជាប្រមុខ
ភ័យខ្លាចនឹងទុក្ខដូចគ្នានឹងសេះ ។
ត្រូវមានស្មារតីរៀនធម៌វិន័យ
តាំងពីក្មេងវ័យឱ្យមានចំណេះ
ហើយប្រព្រឹត្តតាមកុំខ្ជិលអាំងផេះ
ពេលឈ្នះកិលេសនិព្វានរង់ចាំ ។

*កំណាព្យបទពាក្យ ៨ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

## គាថាទី ២២

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវសុខសាមណេរ ទើបត្រាស់នូវព្រះគាថានេះថា

**ឧទកំ ហិ នយន្តិ នេត្តិកា**

**ឧសុការា នមយន្តិ តេជនំ**

**ទារុំ នមយន្តិ តច្ឆកា**

**អត្តានំ ទមយន្តិ សុព្វតា ។**

ធម្មតាអ្នកបង្ហូរ តែងបង្ហូរទឹក អ្នកធ្វើព្រួញតែងពត់ព្រួញ (ឱ្យត្រង់) អ្នកចាំង តែងចាំងឈើ អ្នកមានវត្តល្អ តែងទូន្មានខ្លួន ។

# 22. THE GOOD CONTROL THEMSELVES

Irrigators lead the waters. Fletchers bend the shafts. Carpenters bend the wood. The virtuous control themselves.

អ្នកបង្ហូរទឹក តែងតែគិតនឹក ឱ្យទឹកហូរទៅ
កាន់ទីកន្លែង ដែលខ្លួនសំដៅ ទីរាក់ឬជ្រៅ
នាំទឹកទៅបាន ។

អ្នកធ្វើជាងចាំង ផ្ចិតផ្ចង់ជាខ្លាំង មិនប្រហែសប្រាណ
ឬអ្នកធ្វើព្រួញ ក៏មិនមែនស្មាន គឺសុទ្ធតែបាន
វាស់វែងដោយល្អ ។

ឯអ្នកប្រតិបត្តិ ក៏ត្រូវប្រយ័ត្ន កុំកាត់តំណ
នៃការព្យាយាម ខាត់ចិត្តឱ្យស ទើបបានផលល្អ
រសធមិនិព្វាន ។

*កំណាព្យបទកាកគតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២៣[(១)]

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវស្ត្រីទាំងឡាយ ជាសម្លាញ់របស់នាងវិសាខា ទើបត្រាស់នូវព្រះគាថានេះថា

**កោ នុ ហាសោ កិមានន្ទោ**
**និច្ចំ បជ្ជលិតេ សតិ**
**អន្ធការេន ឱនទ្ធា**
**បទីបំ ន គវេសថ ។**

កាលបើលោកសន្និវាស ត្រូវភ្លើងមានរាគៈជាដើម ឆេះទ្រលោមជានិច្ច ម្ដេចក៏សើច ម្ដេចក៏ត្រេកត្រអាល អ្នកទាំងឡាយត្រូវងងឹតគឺអវិជ្ជារួបរឹតហើយ (ម្ដេចឡើយ) ក៏មិនស្វែងរកប្រទីបគឺប្រាជ្ញា ។

---

១-បើរាប់តាមលំដាប់ក្នុងជរាវគ្គ ត្រូវជាគាថា ទី ១

## 23. SEEK THE LIGHT

What is laughter, what is joy, when the world is ever burning[1]? Shrouded by darkness, would you not seek the light?

---

1. This world is perpetually consumed with the flames of passions. It is completely shrouded by the veil of ignorance. Being placed in such a world, the wise should try to seek the light of wisdom.

កាលបើទ្វីបលោកនេះ ត្រូវភ្លើងឆេះហុយទ្រលោម
សព្វស្ថានទីលើក្រោម ក្ដៅអស់កាលជានិរន្ដរ៍ ។

ហេតុម្ដេចអរសប្បាយ សើចក្អាកក្អាយវង្វេងភាន់
មិនស្វែងទឹកបន្ទាន់ ពន្លត់ភ្លើងឱ្យខីណា ។

អ្នកត្រូវផ្ទាំងងងឹត អវិជ្ជារឹតរួតចិន្ដា
ម្ដេចមិនស្វែងប្រាជ្ញា ជាប្រទីបមកបំភ្លឺ ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

## គាថាទី ២៤

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវនាងសិរិមា ទើបត្រាស់នូវព្រះគាថានេះថា

**បស្ស ចិត្តកតំ ពិម្ពំ**
**អរុកាយំ សមុស្សិតំ**
**អាតុរំ ពហុសង្កប្បំ**
**យស្ស នត្ថិ ធុវំ ឋិតិ ។**

អត្តភាពណា មិនទៀងទាត់ឋិតថេរ អ្នកចូរមើលអត្តភាព (នោះ) ដែលកុសលាកុសលកម្មធ្វើវិចិត្រហើយ ជាកាយពាសពេញដោយដំបៅ ដែលឆ្អឹងបីរយកំណាត់ ផ្គុំគ្នាហើយ ជាអត្តភាពក្តៅក្រហាយជានិច្ច ជាទីរំពឹងត្រិះរិះរបស់ជនច្រើនគ្នា ។

# 24. FOUL IS THIS GAILY DECKED BODY

Behold this beautiful body, a mass of sores, a heaped-up (lump), diseased, much thought of, in which nothing lasts, nothing persists.[1]

---

1. As good as pleasant.

អត្តភាពណា តែងប្រែអនិច្ចា គ្មានការទៀងទាត់
អ្នកចូរពិនិត្យ ឱ្យបានហ្មត់ចត់ កុំបីភ្លាំងភ្លាត់
បាត់បង់ស្មារតី ។

ព្រោះអត្តភាពនេះ បានមកដូច្នេះ ជារូបប្រុសស្រី
ដែលកម្មពីនាយ វិចិត្រជាថ្មី ជនក្នុងលោកីយ៍
រំពឹងគ្រប់គ្នា ។

តែតាមការពិត បើបានពិនិត្យ មើលក្នុងអង្គា
ពាសដោយដំបៅ ឃើញគួរអនិច្ចា ផ្គុំឆ្អឹងចូលគ្នា
បីរយកំណាត់ ។

*កំណាព្យបទកាកគតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ខ.**

# គាថាទី ២៥

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះថេរីឈ្មោះឧត្តរា ទើបត្រាស់ នូវព្រះគាថានេះថា

**បរិជិណ្ណមិទំ រូបំ  រោគនិឌ្ឍំ បភង្គុណំ**

**ភិជ្ជតិ បូតិ សន្ទេហោ មរណន្តំ ហិ ជីវិតំ ។**

រូបនេះគ្រាំគ្រាអស់ហើយ ជាទីសំណាក់នៃរោគជារបស់ពុកផុយ រាងកាយជារបស់ស្អុយ (នេះ) តែងបែកធ្លាយទៅវិញ ព្រោះថាជីវិតមានសេចក្តីស្លាប់ជាទីបំផុត ។

## 25. LIFE ENDS IN DEATH

Thoroughly worn out is this body, a nest of diseases, perishable. This putrid mass breaks up. Truly, life ends in death.

រូបនេះទ្រុឌទ្រោមគ្រាំគ្រាហើយ
មិនឋិតថេរឡើយតែងជរា
ជាទីសំណាក់នៃរោគា
ពុកផុយភង្គាប្រែបែកធ្លាយ ។
ជារូបមានក្លិនស្អុយអសោចិ៍
មិនអន់ជាងខ្មោចអសុរកាយ
ព្រោះថាជីវិតតែងអន្តរាយ
មរណៈទម្លាយចុងបញ្ចប់ ។

*កំណាព្យបទពាក្យ ៧ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

# គាថាទី ២៦

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុអ្នកមានសេចក្តីស្មានហួសច្រើនរូប ទើបត្រាស់នូវព្រះគាថានេះថា

**យានិមានិ អបត្ថានិ**

**អលាពូនេវ សារទេ**

**កាបោតកានិ អដ្ឋីនិ**

**តានិ ទិស្វាន កា រតិ ។**

ឆ្អឹងទាំងឡាយណា មានសម្បុរដូចសត្វព្រាបដែលគេចោលហើយ ដូចផ្លែឃ្លោកក្នុងសរទកាលសេចក្តីត្រេកអរអ្វីហ្ន៎ (របស់អ្នកទាំងឡាយ) ព្រោះតែឃើញឆ្អឹងទាំងឡាយនោះ ។

# 26. WHAT DELIGHT IN SEEING WHITE BONES?

Like gourds cast away in autumn are these dove-hued bones. What pleasure is there in looking at them?

រាងកាយសត្វទាំងឡាយ　គង់បែកធ្លាយរាល់រូបប្រាណ
គេចោលទីស្មសាន　ខានរស់នៅក្នុងគ្រឹហា ។

កាលត្រូវត្រជាក់ក្តៅ　ក៏ក្លាយទៅរូបគ្រាំគ្រា
ឆ្អឹងសពេញពសុធា　បែកអង្គាឆ្អឹងរាយប៉ាយ ។

ត្រេកអរដូចម្តេចហ្ន៎　នឹងគំនរឆ្អឹងទាំងឡាយ
មិនគួរអរសប្បាយ　ត្រាយរកផ្លូវនិព្វានវិញ ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

## គាថាទី ២៧

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះនាងរូបនន្ទា ទើបត្រាស់នូវព្រះគាថានេះថា

**អដ្ឋីនំ នគរំ កតំ មំសលោហិតលេបនំ**

**យត្ថ ជរា ច មច្ចុ ច មានោ មក្ខោ ច ឱហិតោ ។**

សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្តីប្រកាន់ខ្លួន និងសេចក្តីលុបគុណប្រជុំចុះក្នុងសរីរៈណា ( សរីរៈនោះ) ដែលកុសលាកុសលកម្មធ្វើហើយ ឱ្យជានគររបស់ឆ្អឹងទាំងឡាយ ជាគ្រឿងប្រឡាក់ដោយសាច់និងឈាម ។

# 27. THIS BODY IS COMPOSED OF FLESH AND BLOOD

Of bones is (this) city made, plastered with flesh and blood. Herein are stored decay, death, conceit, and detraction.

សេចក្ដីគ្រាំគ្រា   សេចក្ដីមរណា   ការប្រកាន់ខ្លួន
និងការមិនដឹង   រមិលគុណផ្នួន   ឋិតនៅមាំមួន
ក្នុងសរីរៈណា ។

សរីរៈនោះ   ជាទីធ្លាក់ចុះ   របស់ហីនា
ដែលកម្មពីមុន   វិចិត្ររចនា   ប្រមូលបានជា
អដ្ឋិនគរ ។

ជាគ្រឿងចងលាម ដោយសាច់និងឈាម សុទ្ធសឹងមិនល្អ
ហេតុម្ដេចវង្វេង   រីករាយត្រេកអរ   បើសុទ្ធជាធមិ
ហីនាយ៉ាងនេះ ?

*កំណាព្យបទកាកគតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២៨

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះនាងមល្លិកាទេវី ទើបត្រាស់នូវព្រះគាថានេះថា

**ជីរន្តិ វេ រាជរថា សុចិត្តា**
**អថោ សរីរម្បិ ជរំ ឧបេតិ**
**សតញ្ច ធម្មោ ន ជរំ ឧបេតិ**
**សន្តោ ហវេ សព្ភិ បវេទយន្តិ ។**

រាជរថទាំងឡាយ ដ៏វិចិត្រល្អ រមែងគ្រាំគ្រា សូម្បីសរីរៈក៏ដល់នូវសេចក្តីគ្រាំគ្រាដូចគ្នា ទើបឯធមិរបស់សប្បុរសទាំងឡាយ មិនដល់នូវសេចក្តីគ្រាំគ្រា (ដូច្នោះ) ទេ សប្បុរសទាំងឡាយ តែងនិយាយឱ្យពួកសប្បុរសផងគ្នាដឹងបាន ។

# 28. RIGHTEOUSNESS DOES NOT WEAR AWAY

Even ornamented royal chariots wear out. So too the body reaches old age. But the Dhamma[1] of the Good grows not old. Thus, indeed say the Saints[2] among themselves.

---

1. The nine supramundane states are the four Paths, the four Fruits and Nibbāna.
2. Such as the Buddhas.

រាជរថទាំងឡាយដែលវិចិត្រល្អ

នាយសារថីបរគង់ប្រែគ្រាំគ្រា

សូម្បីសរីរៈសត្វលោកគ្រប់គ្នា

តែដល់វេលាគ្រាំគ្រាទាំងអស់ ។

ឯធម៌របស់សប្បុរសទាំងឡាយ

មិនដែលបែកធ្លាយជរាម្តងសោះ

ទោះពេលកន្លងរាប់ឆ្នាំមិនអស់

ក៏លោកអាចគាស់មកបង្ហាញបាន ។

*កំណាព្យបទពាក្យ ៨ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ខ.**

## គាថាទី ២៩

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវលោឡុទាយិត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**អប្បស្សុតាយំ បុរិសោ**

**ពលិពទ្ទោវ ជីរតិ**

**មំសានិ តស្ស វឌ្ឍន្តិ**

**បញ្ញា តស្ស ន វឌ្ឍតិ ។**

បុរសអ្នកមិនមានការចេះដឹងនេះ តែងចាស់ (ឥតអំពើ) ដូចគោបំរើ សាច់របស់វា តែងចម្រើនឡើង តែប្រាជ្ញារបស់វា មិនចម្រើនឡើយ ។

# 29. ONE WITH LITTLE LEARNING LACKS WISDOM

The man of little learning grows old like the ox. His muscles grow; his wisdom grows not.

កើតមកជាមនុស្សតែខ្វះប្រាជ្ញា
ខ្វះសីលសិក្ខាខ្វះការពិសោធន៍
ពីក្មេងដល់ចាស់ប៉ះនៅតែលោត
ចាស់ខ្លួនតែឆោតពិតដូចគោចាស់ ។
មនុស្សខ្លះរស់នៅចម្រើនតែសាច់
មិនអាចសម្រេចការងារបានច្បាស់
ធ្វើអ្វីនិយាយអ្វីចាំតែគេដាស់
ពិតដូចគោចាស់គ្មានខុសសោះឡើយ ។

*កំណាព្យបទពាក្យ ៨ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ៣០

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្បែរគល់នៃពោធិព្រឹក្ស ទ្រង់ប្រារព្ធនូវប្រាជ្ញាជាគ្រឿងត្រាស់ដឹងដំបូង ទើបត្រាស់នូវព្រះគាថានេះថា

**អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។**
**គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**
**សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ**
**វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។**

កាលតថាគតមិនទាន់បានជួបប្រទះ (ពោធិ-ញ្ញាណរវល់តែ) ស្វះស្វែងរកជាងផ្ទះគឺតណ្ហា អ្នកធ្វើផ្ទះ

គឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្ដ មានជាតិដ៏ច្រើន សេចក្ដីកើត ជាទុក្ខរឿយ ៗ ។

នៃជាងផ្ទះ អ្នកឯងធ្វើផ្ទះគឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ(របស់តថាគត)ទៀត មិនបានឡើយ ឆ្អឹងជំនីរគឺកិលេសរបស់អ្នកទាំងអស់តថាគតកាច់បំបាក់អស់ហើយ ដម្បូលផ្ទះគឺអវិជ្ជាតថាគតកំចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វានដែលមានសង្ខារប្រាសហើយ តថាគត បានដល់ធមិជាគ្រឿងក្ស័យតណ្ហា ទាំងឡាយហើយ ។

# 30. CRAVING IS THE BUILDER OF THIS HOUSE

Through many a birth I wandered in saṁsāra,[1] seeking, but not finding, the builder of the house. Sorrowful is it to be born again and again.

---

1. These two verses, the first paean of joy (*udāna*) uttered by the Buddha immediately after His Enlightenment, are not found elsewhere. The Venerable Ānanda heard them from the lips of the Buddha and they have been inserted here.

Here the Buddha admits his past wanderings in existence which entails suffering, a fact which evidently proves the belief in rebirth. He was compelled to wander, and consequently to suffer, so long as he could not discover the architect who built this house, the body. In His final birth He discovered by His own intuitive wisdom the elusive architect dwelling not outside but within the recesses of His own heart. The architect was Craving or Attachment (*taṇhā*) a self-created force, a mental element latent in all. The discovery of the architect is the eradication of craving by attaining Arahanthood which, in this utterance, is alluded to as the end of craving. →

O house-builder! Thou art seen. Thou shalt build no house again. All thy rafters are broken. Thy ridge-pole is shattered. My mind has attained the unconditioned. Achieved is this end of craving.

---

The rafters of this self-created house are the defilements (*kilesa*). The ridge-pole that supports the rafters is ignorance (*avijjā*), the root cause of all defilements. The shattering of the ridge-pole of ignorance by wisdom results in the complete demolition of the house. The ridge-pole and the rafters are the material with which the architect builds this undesired house. With their destruction the architect is deprived of the wherewithal to rebuild the house which is not wanted. With the demolition of the house the mind attains the Unconditional which is Nibbāna.

កាលតថាគតមិនទាន់បានត្រាស់

ស្វែងរកជាងផ្ទះពោលគឺតណ្ហា

មកសាងអត្តភាពនៅក្នុងសង្សារ

មានទុក្ខខ្លោចផ្សាច្រើនជាអនេក ។

នែរើយជាងផ្ទះយើងឃើញអ្នកហើយ

អ្នកមិនអាចឡើយនឹងបំភាន់ភ្នែក

ឆ្អឹងជំនីរអ្នកយើងផាក់បំបែក

ដម្បូលគ្រប់ផ្នែកយើងរើចោលអស់ ។

ចិត្តតថាគតបានដល់និព្វាន

ជាឋានពុំមានសង្ខារទាំងអស់

ឯបង្អែកអ្នកបាក់គ្មានសល់សោះ

យើងលែងរងគ្រោះព្រោះអ្នកទៀតហើយ ។

*កំណាព្យបទពាក្យ ៨ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

# គាថាទី ៣១

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងព្រៃជាទីឱ្យនូវអភ័យដល់ម្រឹគ ឈ្មោះឥសិបតនៈ ទ្រង់ប្រារព្ធនូវសេដ្ឋីបុត្រអ្នកមានទ្រព្យច្រើន ទើបត្រាស់នូវព្រះគាថានេះថា

**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**

**ជិណ្ណកោញ្ចាវ ឈាយន្តិ ខីណមច្ឆេវ បល្លលេ ។**

**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**

**សេន្តិ ចាបាតិខីណាវ បុរាណានិ អនុត្ថុនំ ។**

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យ ក្នុងកាលខ្លួននៅជាកំឡោះក្រមុំ រមែងសញ្ជប់សញ្ជឹង ដូចសត្វក្រៀលចាស់ សំកុកនៅក្នុងភក់ដែលអស់ត្រីហើយ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យ ក្នុងកាលខ្លួននៅកំឡោះក្រមុំ រមែងដេកថ្ងូរ សោកស្តាយទ្រព្យចាស់ទាំងឡាយ ដូចព្រួញដែលផុតចាកខ្សែបន្នោះដូច្នោះ ។

# 31. THEY REGRET WHO DO NOT PROGRESS MATERIALLY AND SPIRITUALLY

They who have not led the Holy Life, who in youth have not acquired wealth, pine away like old herons at a pond without fish.

They who have not led the Holy Life, who in youth have not acquired wealth, lie like wornout bows, sighing after the past.

ពួកជនពាលទាំងឡាយ ងប់សប្បាយពេលខ្លួនក្មេង
គេខំឯងដើរលេង មិនប្រឹងស្វែងសម្បត្តិទ្រព្យ ។

ពេលចាស់ដេកសញ្ជឹង គិតរំពឹងក្រែងមានភ័ព្វ
អង្គុកជិតខាងតែងស្ងប់ រស់ដូចងាប់ព្រោះគិតខ្លី ។

ចង់ស្វែងរកទីពឹង តែមិនដឹងជាធ្វើអ្វី
ដូចកុកដែលអត់ត្រី ក្នុងបឹងភក់រីងស្ងួតហែង ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* **ស.ស.ជ.**

# គាថាទី ៣២[១]

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង ភេសកឡាវ័ន ទ្រង់ប្រារព្ធនូវពោធិរាជកុមារ ទើប ត្រាស់នូវព្រះគាថានេះថា

**អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ**
**តិណ្ណមញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ ៕**

បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួន នោះឱ្យល្អ គួរស្ងួនគ្រងខ្លួនទុកក្នុងវ័យទាំង ៣ វ័យ ណាមួយ ។

---

១-បើរាប់តាមលំដាប់ក្នុងអត្តវគ្គ ត្រូវជាគាថា ទី ១

## 32. BE VIGILANT

If one holds oneself dear, one should protect oneself well. During every one of the three watches (of life) the wise man should keep vigil (against evil).

បើជាតិជាបណ្ឌិត មានគំនិតគិតពិចារណ៏
ដឹងថាខ្លួននេះណា គួរស្នេហាពេកកន្លង ។
ត្រូវចេះថែរក្សា អង្គអាត្មាកុំឱ្យឆ្គង
លះបង់កម្មសៅហ្មង ចេះចងក្រងខ្សែជីវិត ។
វយៈការរស់នៅ បើចែកទៅមានបីពិត
បឋមនាំបង្អិត ចូលទៅជិតវ័យមជ្ឈិម ។
ចុងក្រោយវ័យជរា បាលីថាវ័យបច្ឆិម
ជាវ័យអស់សង្ឃឹម មិនក្លាខ្លាំងដូចក្មេងវ័យ ។
ទោះវ័យណាក៏ដោយ កុំធ្វេសធ្វោយភ្លេចស្មារតី
ព្រោះសត្វលោកគ្រប់វ័យ សុទ្ធចំណីមច្ចុមារ ។
ត្រូវចេះស្ងួនគ្រងខ្លួន ពួនពីបាបគ្រប់ប្រការ
គ្រប់វ័យកុំភ្លេចណា ព្រោះមរណាមើលមិនឃើញ ។

*កំណាព្យបទព្រហ្មគីតិ ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# និធិកណ្ឌសូត្រ

និធឹ និធេតិ បុរិសោ គម្ភីរេ ឱទកន្តិកេ
អត្ថេ កិច្ចេ សមុប្បន្នេ អត្ថាយ មេ ភវិស្សតិ
រាជតោ វា ទុរុត្តស្ស ចោរតោ បីឡិតស្ស វា
ឥណស្ស វា បមោក្ខាយ ទុព្ភិក្ខេ អាបទាសុ វា
ឯតទត្ថាយ លោកស្មឹ និធិ នាម និធិយ្យតិ ៗ

បុរសកប់កំណប់ទ្រព្យទុកក្នុងទីជ្រៅ ជាទីបំផុតនៃទឹក ដោយគិតថា កាលបើកិច្ចដែលត្រូវការកើតឡើងហើយ ទ្រព្យនេះនឹងបានជាប្រយោជន៍ដល់អាត្មាអញ ដែលត្រូវពួកបច្ចាមិត្រពោលបង្កាច់ នឹងបានដោះខ្លួនចេញពីស្តេច ឬត្រូវចោរបៀតបៀន នឹងបានដោះខ្លួន

ចេញពីចោរ នឹងបានដោះបំណុល ឬ ក្នុងពេលទុរភិក្ស ឬក៏ ក្នុងកាលអន្តរាយទាំងឡាយ ធម្មតាកំណប់ដែលគេកប់ទុកក្នុងលោក ដើម្បីប្រយោជន៍នេះឯង ។

តាវស្សុ និហិតោ សន្តោ គម្ភីរេ ឧទកន្តិកេ
ន សព្វោ សព្វទាយេវ តស្ស តំ ឧបកប្បតិ
និធិ វា ឋានា ចវតិ សញ្ញា វាស្ស វិមុយ្ហតិ
នាគា វា អបនាមេន្តិ យក្ខា វាបិ ហរន្តិ នំ
អប្បិយា វាបិ ទាយាទា ឧទ្ធរន្តិ អបស្សតោ
យទា បុញ្ញក្ខយោ ហោតិ សព្វមេតំ វិនស្សតិ ។

កំណប់ដែលបុគ្គលកប់ក្នុងទីជ្រៅ មានទីបំផុតទល់នឹងទឹកដល់ម្លោះ កំណប់ទ្រព្យទាំងអស់នោះ ក៏មិនសម្រេចដល់បុគ្គលនោះសព្វកាលទេ ដ្បិតថាកំណប់ទ្រព្យ រមែង

ឃ្លាតទៅចាកទីខ្លះ សេចក្ដីចំណាំរបស់បុគ្គលនោះ រមែងវង្វេងទៅខ្លះ នាគទាំងឡាយ រមែងនាំជញ្ជូនទៅខ្លះ ពុំនោះសោត ពួកយក្សនាំយកទ្រព្យនោះទៅខ្លះ អ្នកទទួលមតិកដែលមិនជាទីស្រឡាញ់ រមែងគាស់យកនូវកំណប់ទ្រព្យនោះ កាលខ្លួនមិនបានឃើញខ្លះ ខ្លួនអស់បុណ្យទៅវេលាណា កំណប់ទ្រព្យទាំងអស់នោះ រមែងវិនាសបាត់បង់ទៅក្នុងវេលានោះ ។

**យស្ស ទានេន សីលេន សញ្ញមេន ទមេន ច និធិ សុនិហិតោ ហោតិ ឥត្ថិយា បុរិសស្ស វា ចេតិយម្ហិ ច សង្ឃេ វា បុគ្គលេ អតិថីសុ វា មាតរិ បិតរិ វាបិ អថោ ជេដ្ឋម្ហិ ភាតរិ ឯសោ និធិ សុនិហិតោ អជេយ្យោ អនុគាមិកោ**

**បហាយ គមនីយេសុ ឯតំ អាទាយ គច្ឆតិ**

**អសាធារណមញ្ញេសំ អចោរហរណោ និធិ ។**

កំណប់ទ្រព្យដែលស្ត្រី ឬ បុរសណា បានកប់ទុកល្អ ហើយ ដោយទាន សីល ដោយការសង្រួម និងដោយការទូន្មានខ្លួន ក្នុងចេតិយ ឬ ក្នុងសង្ឃ ឬ ក្នុងបុគ្គល ឬ ក្នុងពួកភ្ញៀវ ឬមួយក្នុងមាតា ក្នុងបិតា ឬថា ក្នុងបងប្រុស-ស្រី ដែលជាច្បង កំណប់ទ្រព្យនុ៎ះ ចាត់ជាកំណប់ទ្រព្យដែលកប់ទុកប្រពៃហើយ នរណា ៗ មិនគប្បីផ្ចាញ់បាន ជាកំណប់ទ្រព្យ ដែលជាប់តាមខ្លួនទៅ កាលភោគៈទាំងឡាយដែលខ្លួនត្រូវលះបង់ហើយទៅ ខ្លួនរមែងកាន់យកនូវកំណប់ទ្រព្យគឺបុណ្យនុ៎ះទៅ កំណប់

ទ្រព្យគឺបុណ្យ មិនទូទៅដល់ពួកជនដទៃ ជារបស់ដែលចោរលួចទៅមិនបាន ។

**កយិរាថ ធីរោ បុញ្ញានិ យោ និធិ អនុគាមិកោ**

**ឯស ទេវមនុស្សានំ សព្វកាមទទោ និធិ**

**យំ យំ ទេវាភិបត្ថេន្តិ សព្វមេតេន លព្ភតិ ៕**

កំណប់ទ្រព្យ គឺបុណ្យណាជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញ គួរធ្វើនូវកំណប់ទ្រព្យគឺបុណ្យនោះ កំណប់ទ្រព្យគឺបុណ្យនុ៎ះ ឱ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងដល់ទេវតានិងមនុស្សទាំងឡាយ ពួកទេវតានិងមនុស្សទាំងឡាយប្រាថ្នាណាស់នូវផលណា ៗ ផលទាំងពួងនោះ ៗ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។

**សុវណ្ណតា សុសរតា សុសណ្ឋានំ សុរូបតា**

**អាធិបច្ចំ បរិវារោ សព្វមេតេន លព្ភតិ ។**

ភាពជាអ្នកមានសម្បុរផូរផង់ មានសម្លេងពីរោះ ទ្រង់ទ្រាយល្អ រូបល្អ ជាអធិបតី មានយសបរិវារ ផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។

**បទេសរជ្ជំ ឥស្សរិយំ ចក្កវត្តិសុខំ បិយំ**

**ទេវរជ្ជម្បិ ទិព្វេសុ សព្វមេតេន លព្ភតិ ។**

ភាពជាស្តេចប្រទេសរាជ ឥស្សរិយយស សេចក្តីសុខរបស់ស្តេចចក្រពត្តិជាទីស្រឡាញ់ ភាពជាស្តេចនៃទេវតាក្នុងទេពនិកាយទាំងឡាយ ផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។

**មានុស្សិកា ច សម្បត្តិ ទេវលោកេ ច យា រតិ**

**យា ច និព្វានសម្បត្តិ សព្វមេតេន លព្ភតិ ។**

សម្បត្តិជារបស់មនុស្សណាផង សេចក្តីត្រេកអរក្នុងទេវលោកណាផង សម្បត្តិគឺព្រះនិព្វានណាផង សម្បត្តិទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។

**មិត្តសម្បទមាគម្ម យោនិសោ ចេ បយុញ្ជតោ**

**វិជ្ជាវិមុត្តិវសីភាវោ សព្វមេតេន លព្ភតិ ។**

ភាពនៃបុគ្គលកាលអាស្រ័យមិត្តសម្បទា បើប្រកបសេចក្តីព្យាយាម ដោយឧបាយដែលត្រូវ ជាអ្នកស្ទាត់ក្នុងវិជ្ជានិងវិមុត្តិ ឥដ្ឋផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនោះ ។

**បដិសម្ភិទា វិមោក្ខា ច យា ច សាវកបារមី**

**បច្ចេកពោធិ ពុទ្ធភូមិ សព្វមេតេន លព្ភតិ ។**

បដិសម្ភិទា វិមោក្ខ សាវកបារមីញាណ បច្ចេកពោធិញ្ញាណ និងពុទ្ធភូមិណា ៗ ឥដ្ឋផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។

**ឯវំ មហត្ថិកា ឯសា យទិទំ បុញ្ញសម្បទា**

**តស្មា ធីរា បសំសន្តិ បណ្ឌិតា កតបុញ្ញតន្តិ ។**

បុញ្ញសម្បទានេះ ឱ្យសម្រេចប្រយោជន៍ដ៏ធំ ដោយប្រការដូច្នេះ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ ជាធីរជន ទើបសរសើរនូវភាពនៃបុគ្គលជាអ្នកមានបុណ្យធ្វើទុកហើយ ។

*ដកស្រង់ចាកគម្ពីរ សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ និធិកណ្ឌសូត្រ បិដកលេខ ៥២ ទំព័រទី ១៥ ដល់ទី ១៨*

# គោតមប្រវត្តិ

ខ្ញុំសូមថ្វាយវន្ទា ព្រះសាស្តាដ៏មានបុណ្យ
និងសូមគោរពគុណ គ្រាព្រះអង្គចុះចាកឋាន ។
មកចាប់ផ្ទៃមាតា ស្រីស្រីង្គាររស្រស់កល្យាណ
កាលនោះមហាជនបាន សុខក្សេមក្សាន្តព្រោះបារមី ។
ក្នុងថ្ងៃព្រហស្បតិ៍អា- សាធមាសាពេញបូណ៌មី
រកាជាឆ្នាំថ្មី សុខសិរីដល់ជនា ។
កាលបាន១០ខែហើយ ព្រះគុណអើយកើតអស្ចារ្យ
នៅនាដងព្រឹក្សា ឈ្មោះហៅថាព្រៃសាលវ័ន ។
កក្រើកផែនពសុធា មានទេវតារាប់រយពាន់
ស្ថិតនៅក្នុងតំបន់ នៃឧទ្យានលុម្ពិនី ។

ឆ្នាំចពិសាខនា ថ្ងៃសុក្រជាពេញបូណ៌មី
ថ្ងៃនោះព្រះជិនស្រី ទ្រង់ប្រសូតឥតមានព្រួយ ។
កាលសិទ្ធត្ថក្សត្រា មានវស្សាដប់ប្រាំមួយ
បិតាបានលើកស្នួយ អភិសេកនឹងស្រីង្គារ ។
នារីស្រស់កល្យាណ អ្នកផងបានស្គាល់គ្រប់គ្នា
ថាឈ្មោះនាងពិម្ពា ស្រស់សោភាលើសលែងក្រៃ ។
កាលនោះក្នុងឆ្នាំឆ្លូវ ត្រូវថ្ងៃសៅរ៍មានសិរី
អាសាធពេញបូណ៌មី ក្សត្រាថ្លៃបានសុខា ។
ស្ដេចមានព្រះរាជបុត្រ បរិសុទ្ធភ័ក្ត្រស្រស់ថ្លា
គួរឱ្យព្រះរាជា ស្ដេចជំពាក់ចិត្តពេកក្រៃ ។
តែទ្រង់បានកាត់ផ្ដាច់ ទ្រង់សម្រេចព្រះហឫទ័យ

ថាត្រូវកាត់អាល័យ ពីបុត្រថ្លៃមួយគ្រាណា ។

បើបិតាបានត្រាស់ វិលរហ័សរកបុត្រា

មកប្រោសស្ងួនពុំងា ចាកសង្សារណាបុត្រថ្លៃ ។

កាលនោះថ្ងៃព្រហស្បតិ៍ ក្នុងឆ្នាំថោះមានសិរី

អាសាធពេញបូណ៌មី ក្សត្រាថ្លៃចេញបព្វជ្ជា ។

កាលបានបព្វជ្ជាហើយ មិនព្រងើយខំឧស្សាហ៍

ធ្វើទុក្រកិរិយា គ្មាននរណាធ្វើដូចអី ។

បានត្រាស់ឆ្នាំរកា ពិសាខាពុធបុណ្ណមី

ជាថ្ងៃព្រះជិនស្រី មានសិរីឈ្នះក្រុងមារ ។

ត្រាស់ដឹងបានពីរខែ ទ្រង់គ្មាន់គ្នេរប្រោសទេសនា

ប្រោសបញ្ចវគ្គិយា នាកណ្ដាលដងព្រឹក្សព្រៃ ។

គឺក្នុងឆ្នាំរកា អាសាធមាសាបុណ្ណមី
ថ្ងៃសៅរ៍ព្រះជិនស្រី ផ្ដើមពោលស្ដីធម៌ទេសនា ។
ក៏ជាថ្ងៃកំណើត សង្ឃបានកើតក្នុងលោកា
សាវ័កព្រះសាស្ដា មានរហូតដល់សព្វថ្ងៃ ។
នាថ្ងៃមួយនោះណា គួរសោកាណាស់ម្ចាស់ថ្លៃ
គឺថ្ងៃព្រះជិនស្រី កាត់ព្រះទ័យដាក់សង្ខារ ។
គឺក្នុងថ្ងៃអាទិត្យ ឆ្នាំម្សាញ់ពិតមាឃមាសា
នៅចំពោះមុខមារ នាបាវាលចេតិយ ។
បីខែកន្លងទៅ មិនឈប់នៅយឺនយូរអី
ដល់ថ្ងៃព្រះជិនស្រី ទ្រង់និព្វានចាកលោកា ។

គឺក្នុងឆ្នាំនោះឯង    មានការផ្សេងតែមាសា
គឺខែពិសាខនា    ថ្ងៃអង្គារពេញបូណ៌មី ។
ដោយអំណាចអានុភាព    ដែលខ្ញុំក្រាបថ្វាយវន្ទិយ៏
ទឹកគុណព្រះមុនី    សូត្រប្រវត្តិព្រះសាស្តា ។
សូមឱ្យសម្រេចបុណ្យ    ដែលជាគុណល្អថ្លៃថ្លា
អន្ទោលក្នុងសង្សារ    សូមប្រាថ្នាជួបបណ្ឌិត ។
សូមជួបព្រះសិអារ្យ    ជាសាស្តាដ៏ពិសិដ្ឋ
សូមចាក់ធ្លុះធមិពិត    សមដូចចិត្តប្រាថ្នាហោង ។

ព.ស. ២៥៤៦

**ស.ស.ជ.**

# កុំភ្លេចខ្លួន

ធម៌អកុសលផ្តល់ក្តីទុក្ខ    ឱ្យឃ្លាតចាកសុខក្នុងសួគ៌ឋាន
ស៊កសៀតរោលរាលចិត្តសន្តាន    ឱ្យឆ្ងាយនិព្វានគ្មានគោលដៅ ។
បើចង់ត្រជាក់ត្រូវកុំដុត    ចូរជៀសឱ្យផុតពួកធម៌ខ្មៅ
បើខ្លាចកុំផ្លោះចូលរណ្តៅ    បើមិនចង់ខ្លៅត្រូវសិក្សា ។
រៀនធម៌វិន័យលៃឱ្យចំ    មិនត្រូវបន្លំបួមសាសនា
កុំប្រញាប់ជឿក្បួនតម្រា    បើឮគេថាត្រូវតែគិត ។
បើជឿត្រូវជឿឱ្យសមរម្យ    បើខំត្រូវខំសង្កេតចិត្ត
បើដើរត្រូវដើរតាមបណ្ឌិត    បើគិតត្រូវគិតរឿងសង្ខារ ។
បើបានកុំភ្លេចគិតរឿងបង់    បើចង់កុំភ្លេចរឿងសោកា
បើជួបកុំភ្លេចរឿងបែកណា    បើបានសុខាកុំភ្លេចខ្លួន ។

ព.ស. ២៥៥១

**ស.ស.ជ.**

- ១២០ -

# កំណាព្យផ្សេងៗ

## តុលាការកម្ម

ចៅក្រមលំអៀងឥតពិចារណា

ជឿអ្នកឥស្សាមុសាបំភ័ន្ត

ស្តាប់ឮត្រឹមរយពោលលយដល់ពាន់

តែកម្មតាមទាន់ផាកទាំងអស់គ្នា ។

*ដោយឧបាសិកា ឱម លក្ខណា*

# សត្វលោកស្មើគ្នាដោយធម៌

បើគិតតាមឋានៈ　　លាភយសស័ក្តិខុសដាច់គ្នា
នរកប្រេតព្រហ្មា　　មនុស្សទេវតាសត្វតិរច្ឆាន ។
សឹងកើតដោយបាបបុណ្យ　　ធ្វើពីមុននាំឱ្យបាន
ចាប់ភពគ្រប់ទីស្ថាន　　ល្អសាមាន្យខ្ពស់និងទាប ។
តែកាលបើទោសៈ　　លោភមោហៈចូលពេញព្រៀប
ចិត្តជនខ្ពស់ឬទាប　　ធម៌ថោកជ្រាបទាបស្មើគ្នា ។

*ដោយឧបាសិកា ឱម លក្ខណា*

## ខ្លួនគេទើបដឹងច្បាស់

សេចក្តីបរិសុទ្ធនិងសៅហ្មង   របស់អ្នកផងគេតែងដឹង
ខ្លួនគេមិនបាច់យើងខំប្រឹង   ជួយព្រួយអរខឹងជំនួសឡើយ ។

*ដោយឧបាសិកា ឌិម លក្ខណា*

## ពាក្យរាយរាយនាំធ្លាក់នរក

បើចង់នាំពាក្យត្រូវចេះគិត   ពោលតែពាក្យពិតមានខ្លឹមសារ
កុំមួលបំផ្លើសឥតបានការ   តិរច្ឆានកថាធ្លាក់អបាយ ។

*ដោយឧបាសិកា ឌិម លក្ខណា*

## កុំកើតទុក្ខនឹងកិលេសគេ

ពេលឮពាក្យចោទខុសការពិត ត្រូវប្រយ័ត្នចិត្តកុំខឹង-ត
ព្រះពុទ្ធដីកាថាមនុស្សល្អ មិនគួរបន្តភ្លើងពីគេ ។
អ្នកណាថាខុសអ្នកនោះបាប កម្មកត់ដរាបមិនភ្លេចទេ
កុំកើតទុក្ខនឹងកិលេសគេ ពិនិត្យមើលថែតែចិត្តខ្លួន ។

*ដោយឧបាសិកា ឌិម លក្ខណា*

## ហេតុតែរបស់ខ្ចីគេ

ហេតុតែមិនមែនរបស់យើង ខ្លួនប្រាណដៃជើងឈឺចុកចាប់
ហាមឃាត់អង្វរក៏មិនស្តាប់ ព្រោះអ្នកតែងច្បាប់គឺកម្មផល ។

*ដោយឧបាសិកា ឌិម លក្ខណា*

# លាងចិត្តយើងមុន

ពេលឃើញឡានទឹកមកដល់ហើយ ប្រាប់ថាអ្នកអើយកុំបារម្ភ
ជួយលត់ផ្ទះគេមុនផ្ទះខ្ញុំ គេមានទុក្ខធំខ្ញុំមិនអី ។
យ៉ាងណាពេលចិត្តកើតសៅហ្មង ប្រៀបដូចមានខ្ទងប្រឡាក់ដី
មិនខំដុសលាងបែរជាភ័យ ជួសអ្នកដទៃឯណោះវិញ ។

*ដោយឧបាសិកា **ឱម លក្ខណា***

# គួរលាក់ទោសៈតែក្នុងចិត្ត

ចិត្តសម្បូរអ្វីទើបចែកគេបាន បើចង់ឱ្យទានឱ្យរបស់ល្អ
នៅពេលខឹងក្រោធកុំចែកបន្ត ទោសៈបង្កជាភ្លើងនរក ។

*ដោយឧបាសិកា **ឱម លក្ខណា***

## កុំផ្គាប់លោភៈ

ផ្គាប់ផ្គុនគុណធមិស្ងប់ត្រជាក់ ផ្គាប់ផ្គុនលោភៈទុក្ខច្រើនយ៉ាង
ផ្គាប់កាមញៀនញ៉ាមមិនងាយស្វាង មានតែហត់ខ្លាំងខកគំនិត ។
ផ្គាប់ផ្គុនកាមគុណជាក់ជាស្ដាយ ខាតពេលថៃកាយអប់រំចិត្ត
ផ្គាប់លោកប្រាំមួយយកជាមិត្ត លុះដឹងរឿងពិតជិតហួសពេល ។

*ដោយឧបាសិកា **ឱម លក្ខណា***

## សូមកុំបានធ្លាប់ដូចគេ

ទម្លាប់ពោលលើសស្មានតែអត់ខុស គឺជាបាបគ្រោះ១យ៉ាងដំណំ
ស្ដាប់ឮត្រឹមល្ខៅថាប៊ុនសាលាឃុំ ប្រាថ្នាសូមកុំបានធ្លាប់ដូចគេ ។

*ដោយឧបាសិកា **ឱម លក្ខណា***

# អកុសលកម្មដែលត្រូវវៀរ

រឿងចិត្តអាក្រក់អ្នកដទៃ
មិននាំឱ្យភ័យធ្លាក់អបាយ
ចិត្តបាបក្នុងខ្លួនទើបអន្តរាយ
ត្រូវឆាប់ដោះស្រាយដុសលាងចេញ ។

ពេលមានវិបាកអកុសល
គួរទទួលស្គាល់ថាចំណេញ
អរបានថយបាបលែងនៅពេញ
អកុសលកម្មវិញទើបត្រូវវៀរ ។

*ដោយឧបាសិកា ឱម លក្ខណា*

# ទ្រុងមច្ចុរាជ

អភិធម្មនាំឱ្យដឹងការពិត
យល់ពីជីវិតប្រចាំថ្ងៃ
ជឿជាក់ក្នុងផលឥតសង្ស័យ
កើតពីបច្ច័យហេតុទាំងអស់ ។
ស្គាល់លោកប្រាំមួយដូចស្គាល់កូន
កើតហើយប្រែសូន្យរលត់ស្មោះ
គ្រប់អាយតនៈមិនចន្លោះ
គ្មានអ្វីទៀងសោះត្រូវប្រឹងលះ ។
ចិត្តចេតសិករូបមានដូចគ្នា
តែនៅចងពៀរព្រោះមានះ
ប្រកាន់ហួងហែងបែងយកឈ្នះ
ក្នុងទ្រុងតេជះមច្ចុរាជ ។

*ដោយឧបាសិកា ឱម លក្ខណា*

# ការផ្សេងគ្នារវាងបុថុជ្ជននិងអរិយបុគ្គល

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា   បុថុជ្ជនណាដែលកន្លង
មិនបានអប់រំកាយចិត្តផង   នឹងកើតសៅហ្មងមិនខានឡើយ ។

បុគ្គលដែលមានអវិជ្ជា   លុះសុខវេទនាពាល់ត្រូវហើយ
ក៏មានតម្រេកខ្លាំងឥតស្បើយ   លង់លក់ងប់ដោយក្តីសុខនោះ ។

ពេលសុខវេទនារលត់ទៅ   ក្តីទុក្ខសោកសៅកើតចំពោះ
បុគ្គលដែលជាបុថុជ្ជននោះ   ឱ្យលំបាកហួសខ្សឹកខ្សួលយំ ។

គក់ទ្រូងដល់នូវក្តីវង្វេង   ឆេះក្តៅម្នាក់ឯងដូចភ្លើងភ្នំ
ព្រោះតែប្រមាទភ្លេចអប់រំ   ទើបទុក្ខឆេះងំសង្កត់ចិត្ត ។

ចំណែកបុគ្គលអរិយសាវ័ក   ក្នុងលោកជាអ្នកចេះដឹងពិត
ទោះបានសោយសុខហួសកម្រិត   ក៏មិនលង់ចិត្តចោលគុណធម៌ ។

*ដោយឧបាសិកា ឱម លក្ខណា*

# កុំអាងដុំពពុះទឹក

កូនក្មេងខឹងឡើងអាងតែយំ ចំណែកចាស់ទុំអាងតែស្លាប់
ជនពាលប្រមាទអាងចាក់កាប់ បណ្ឌិតអាងច្បាប់ធម៌វិន័យ ។
ជនខ្លះអាងលាភយសទ្រព្យធន ខ្លះអាងប្រពន្ធកូនស្វាមី
ភ្លេចគិតថាសុទ្ធជាចំណី ភ្លើងខ្យល់ទឹកដីគ្រប់ៗគ្នា ។
ខន្ធប្រាំដោយរោគមកពីនាយ សតិវាយមាយឈឺថាជា
មហាភូតរូបបួនក្លែងផានា ចាំជួយការពារក្នុងសុបិន ។

*ដោយឧបាសិកា ឌិម លក្ខណា*

# តម្រាផ្សំធាតុ

ធ្លាប់ឮថានាងរត់រកអ្នក រីឯខាតលក្ខណ៍រកបាក់អន្យា
ជីទាវរត់រកអ្នកឧកញ៉ា បវរធីតារកមហាក្សត្រ ។
ធាតុខ្មោចនិងខ្មោចរត់រកគ្នា រីពួកទេវតាក៏ស្វែងកាត់
រកទេពធីតាមិនឃ្លាតបាត់ រួមថ្លើមប្រម៉ាត់រស់សុខសាន្ត ។
ធាតុធមិរត់រកធាតុសីលទាន អ្នកធ្វើបាបញៀនសេពគប់បាន
តែនឹងពាលមិត្តចិត្តសាមាន្យ បៀតបៀនរំខានមនុស្សផងគ្នា ។
ល្ងង់រត់រកមិច្ឆាទិដ្ឋិ កើតរោគសតិមើលពុំជា
ពោលមួលដីកាព្រះភគវា ធ្លាក់នរកមួយគ្រាក្រែងជាគ្រាន់ ។

*ដោយឧបាសិកា ឱម លក្ខណា*

# អ្នកមានឧបការៈជួយពិនិត្យអក្ខរាវិរុទ្ធ

| | |
|---|---|
| ធម្មាចារ្យ **គម្ភីរបញ្ញោ** | **ទួច សុធី** |
| ឧទ្ទេសាចារ្យ **សុវណ្ណត្ថេរោ** | **វង្ស ធំព័រ** |
| ភិក្ខុ **កោសលបញ្ញោ** | **ទួច ពិសិដ្ឋ** |
| ឧទ្ទេសាចារ្យ **សីលសំវរោ** | **ស៊ូ សាម៉ុត** |
| សាមណេរ **បញ្ញាបរមោ** | **ឈាត ម៉ុនឆាត** |
| សាមណេរ **ព្រហ្មឃោសកោ** | **ឈិត ម៉ុនធឿន** |
| សាមណេរ **ញាណភទ្ទោ** | **សុខ ទុំដែន** |
| សាមណេរ **ឧត្តិធរោ** | **ជឹម ប៊ុរិន** |
| សាមណេរ **ធម្មកាមតា** | **វន ស៊ុខ** |

# សៀវភៅធម៌ដែលបានរៀបរៀង

## ដោយ ភិក្ខុវជិរប្បញ្ញោ សាន សុជា

| | |
|---|---|
| ១.ព្រះធម្មបទ ៣២ គាថា | ព.ស. ២៥៥១ |
| ២.ដំណើរជីវិត | ព.ស. ២៥៥១ |
| ៣.ព្រះធម្មបទ ៣១ គាថា | ព.ស. ២៥៥០ |
| ៤.អក្ខរវិធីនិងធម៌នមស្ការ | ព.ស. ២៥៥០ |
| ៥.រលកលោកធម៌ | ព.ស. ២៥៥០ |
| ៦.ព្រះធម្មបទ ៣០ គាថា | ព.ស. ២៥៤៩ |
| ៧.ប្រយោជន៍ ៣ ប្រការ | ព.ស. ២៥៤៩ |
| ៨.ជីវិត (Life) | ព.ស. ២៥៤៩ |
| ៩.បងប្អូនជួបគ្នាមួយគ្រាមានន័យ | ព.ស. ២៥៤៨ |
| ១០.អភិធម្មត្ថសង្គហៈ បរិច្ឆេទទី ៤ | ព.ស. ២៥៤៨ |
| ១១.ធម្មសង្គណី តិកមាតិកាសង្ខេប | ព.ស. ២៥៤៨ |
| ១២.ជីវិតពិតជាត្រូវការធម៌ | ព.ស. ២៥៤៦ |
| ១៣.តើនរកមានដែរឬទេ ? | ព.ស. ២៥៤៦ |

ព្រះធម៌គឺជាប្រទីបសម្រាប់បំភ្លឺជីវិតសត្វលោក

# ប៉ុស្តិ៍វិទ្យុដែលកំពុងផ្សព្វផ្សាយព្រះធម៌
# សម្តែងដោយ ភិក្ខុវជិរប្បញ្ញោ សាន សុជា

| ខេត្ត-ក្រុង | ស្ថានីយវិទ្យុ | វេលាផ្សាយ |
|---|---|---|
| សៀមរាប | FM 102.50 MHz | ៥.00 am ⇨ ៥.៣0 am |
| ព្រះវិហារ | FM 99.00 MHz | ៥.៤៥ am ⇨ ៦.១៥ am |
| ស្ទឹងត្រែង | FM 100.50 MHz | ៥.៣0 am ⇨ ៦.00 am |
| កំពង់ធំ | FM 107.30 MHz | ៥.៣0 am ⇨ ៦.00 am |
| ពោធិ៍សាត់ | FM 100.50 MHz | ៦.៣0 pm ⇨ ៧.00 pm |
| តាកែវ | FM 92.50 MHz | ៦.៣0 pm ⇨ ៧.00 pm |

## សុស្សូសំ លភតេ បញ្ញំ

ការស្តាប់ព្រះធម៌ដោយល្អរមែងបាននូវបញ្ញា

# ប៉ុស្តិ៍វិទ្យុដែលកំពុងផ្សព្វផ្សាយព្រះធម៌
# សម្តែងដោយ ភិក្ខុវជិរប្បញ្ញោ សាន សុជា
## (ត)

| ខេត្ត~ក្រុង | ស្ថានីយវិទ្យុ | វេលាផ្សាយ |
|---|---|---|
| កំពង់សោម | FM 92.00 MHz | ៦.៣0 pm ⇨ ៧.00 pm |
| កំពង់ចាម | FM 92.50 MHz | ៧.៣0 pm ⇨ ៨.00 pm |
| ពោធិ៍សាត់ | FM 98.50 MHz | ៧.00 pm ថ្ងៃសីលមួយម៉ោង |
| កំពង់ធំ | FM 88.50 MHz | ៨.00 pm ⇨ ៨.៣0 pm |
| ស្វាយរៀង | FM 103.75 MHz | ៨.៣0 pm ⇨ ៨.៣0 pm |

**សុខា សទ្ធម្មទេសនា**

ការសម្តែងនូវព្រះសទ្ធម្មនាំមកនូវសេចក្តីសុខ